ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ

# UNION COMMERCIAL BANK PLC. (UCB) LENDING PROCESS

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ភ.អ

UNION COMMERCIAL BANK PLC. (UCB) LENDING PROCESS


**គ្រូណែនាំ៖ ឌុំ គឹមស្រី**


**ជំនាញ គណនេយ្យ**


**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈ ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ**

| | |
|---|---|
| គណកម្មការវាយតម្លៃទី១ | គ្រូណែនាំ |
| បេក្ខបណ្ឌិត មាស សំណាង | ឌុំ គឹមស្រ៊ី |
| គណកម្មការវាយតម្លៃទី៣ | គណកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បេក្ខបណ្ឌិត យ៉ាក វុទ្ធី |
| ប្រធានគណកម្មការវាយតម្លៃ និងជានាយក<br>មជ្ឈមណ្ឌលស្រាវជ្រាវ | អនុប្រធានគណកម្មការវាយតម្លៃ និងជានាយករង<br>មជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត ស្រេង ផល្លា |
| **សាកលវិទ្យាធិការ** | សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុម យើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញដែលមានសារៈសំខាន់មួយដែរ សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយ ឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខ ជំនាញសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំ សិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្ត ការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងការត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេត ឃើញថាកិច្ចការងារមួយនេះ មានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិ ញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ដំណើរការនៃការផ្តល់ ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យ អ្នកស្រាវជ្រាវទាំងអស់ បានយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការផ្តល់ឥណទាន របស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់ និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



អ៊ុំ ម៉ាសុភា
ID: B22/430



ឡាយ គង់គា
ID: B22/567



សិត កែវម៉ូលីកា
ID: B22/855



ស្រ៊ន់ ស្រីល័ក្ខ
ID: B22/1504



អាន រ៉ូសា
ID: B22/682

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្ដុះបណ្ដាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ខំ គឹមស្រ៊ី** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិសិត្សបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ានដា ជំនាន់ទី២២៖ សូមធានាអះអាងថាខ្លឹមសារសារណាក្រោមប្រធានបទ"**ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក.អ** " នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធ ឬចម្លងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើតខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩.. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

អ៊ុំ ម៉ាសុភា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ធនាគារសហពាណិជ្ជ ក.អ ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែ មីនា ឆ្នាំ១៩៩៤ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយដែលមានទិសដៅអភិវឌ្ឍមុខរបរខ្នាតតូចបំផុត និងខ្នាតតូច។ បន្ទាប់មកធនាគារក៏បានពង្រីកបណ្តាញប្រតិបត្តិការគ្របដណ្តប់គ្រប់ខេត្តរាជធានី ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងការរកប្រាក់ចំណេញដែលធានាបានមកនូវនិរន្តរភាពហើយបានកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ។

ចំណែកឯការរៀបចំនីតិវិធីក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព ធនាគារបានលើកយកនូវ៤ វិធីសាស្ត្រសម្រាប់វាយតម្លៃប្រភេទសមត្ថភាពឥណទានដូចជា ការវាយតម្លៃលើអតិថិជនឯកជន ការវាយតម្លៃលើអាជីវកម្ម ការកំណត់លក្ខខណ្ឌទូទាត់ ការពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យ។ វិធីសាស្ត្រនីមួយៗ បានបង្ហាញយ៉ាងច្បាស់ អំពីការគ្រប់គ្រងនិងការទប់ស្កាត់របស់ធនាគារ ក្នុងការរៀបចំនីតិវិធីឱ្យមានប្រសិទ្ធភាព នឹងធ្វើឱ្យដំណើរការកាន់តែមានភាពងាយស្រួលដល់អតិថិជិជន។ ចំពោះគណៈកម្មការគ្រប់គ្រងហានិភ័យមានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល គ្រប់គ្រងហានិភ័យដែលអាចប៉ះពាល់ដល់ស្ថាប័នដោយការបង្កើត និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រនឹងប្រព័ន្ធតាមដាន ដើម្បីទប់ស្កាត់ហានិភ័យទាំងហិរញ្ញវត្ថុ ប្រតិបត្តិការ និងទីផ្សារសេដ្ឋកិច្ច។ ព្រមទាំងការបណ្តុះបណ្តាលបុគ្គលិក បង្កើនការគ្រប់គ្រងហានិភ័យនៅទូទាំងអង្គភាព។ ការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យា តាមដានទៅលើហិរញ្ញវត្ថុ នឹងអត្រាការប្រាក់សម្រាប់គ្រប់គ្រងហានិភ័យ។ គោលការណ៍ CEL (Credit Exposure Limit) ត្រូវបានប្រើដើម្បីកំណត់កម្រិតឥណទានទៅអតិថិជន/អាជីវករ ក្នុងគោលបំណងកាត់បន្ថយហានិភ័យ។ រួមមានការបញ្ជាក់កម្រិតឥណទាន ត្រួតពិនិត្យស្ថានភាពបង់ប្រាក់ វាយតម្លៃប្រវត្តិឥណទាន ការចុះបញ្ជីក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងការកំណត់កម្រិតហានិភ័យដែលពាក់ព័ន្ធទៅនឹងប្រភេទនៃការប្រាក់ និងការប្រើប្រាស់ឥណទាន។ វិធីសាស្ត្រទាំងនេះ បានរចនាឱ្យសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ច ថែមទាំងផ្តល់ភាពងាយស្រួលក្នុងការប្រមូលព័ត៌មានពីអតិថិជន ដើម្បីធានាបាននូវប្រព័ន្ធគ្រប់គ្រងហានិភ័យ ដ៏មានប្រសិទ្ធភាពនឹងជួយកាត់បន្ថយហានិភ័យខ្ពស់។

ម្យ៉ាងវិញទៀត យើងបានឃើញថាធនាគារ ក៏មានចំណុចខ្វះខាតបន្តិចបន្តួចផងដែរ ដែលទាក់ទងទៅនឹងផ្នែកសេវាកម្មកម្ចី រវាងអតិថិជននឹងបុគ្គលិកធនាគារ។ ទាំងនេះហើយធ្វើអោយអតិថិជនមួយចំនួនតូចមានចិត្តរារែក ពិបាកសម្រេចចិត្តក្នុងការទទួលយកសេវាកម្មពីធនាគារ។

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ រួចមក ក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ការរកស៊ីរបស់ធនាគារមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំដែលបញ្ជាក់ពីភាពខ្លាំងរបស់ធនាគារ ក្នុងការផ្តល់ទំនុកចិត្តខ្ពស់ដល់អតិថិជន។ ធនាគារគួរតែធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ថា តើអ្នកទទួលឥណទានមានលទ្ធភាពសងទាំងការប្រាក់ នឹងប្រាក់ដើមបានដែរឬទេ? ធនាគារអាចយកជាវត្ថុបញ្ចាំ ឬវត្ថុមានតម្លៃដទៃទៀត លើសពីឥណទានដែលបានផ្តល់ជូន។ ដូចនេះធនាគារអាចធានាមិនអោយមានសំវិធានធនបាត់បង់ឥណទានច្រើនលើសលប់ពេកនោះទេ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i

របានាសម្ព័នក្រុម........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មតិកា........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ........២

១.៣ គោលបំណងនៃការស្រាវជ្រាវ........២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........២

    ១.៤.១ ទំហំដែនកំណត់........២

    ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ........២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ........៣

    ១.៥.១ ការប្រមូលទិន្នន័យ ........៣

    ១.៥.២ ការប្រមូលទិន្នន័យ ........៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ........៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........៤


## ជំពូកទី២
## ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ


២.១ លក្ខណៈទូទៅនៃដំណើរការក្នុងការផ្តល់ឥណទានរបស់ធនាគារ

    ២.១.១ និយមន័យដំណើរការ........ ៥

    ២.១.២ ប្រវត្តិនៃដំណើរការ........ ៥

    ២.១.៣ ប្រភេទនៃដំណើរការ ........ ៥

    ២.១.៤ និយមន័យធនាគារ........ ៦

    ២.១.៥ ប្រវត្តិនៃធនាគារ........៧

២.២ នីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារ ........១០

    ២.២.១និយមន័យឥណទាន ........១០

    ២.២.២ ប្រវត្តិឥណទាន ........១០

២.២.៣ ប្រភេទឥណទាន..........១១
២.២.៤ និយមន័យនីតិវិធី..........១២
២.២.៥ ប្រវត្តិនៃនីតិវិធី..........១២
២.២.៦ សារៈសំខាន់នៃនីតិវិធី..........១៤
២.៣ យុទ្ធសាស្ត្របែបណាខ្លះក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព..........១៥
២.៣.១ និយមន័យយុទ្ធសាស្ត្រការគ្រប់គ្រង..........១៥
២.៣.២ ទ្រឹស្តីយុទ្ធសាស្ត្រការគ្រប់គ្រង..........១៥
២.៣.៣ និយមន័យហានិភ័យឥណទាន..........១៦
២.៣.៤ ប្រវត្តិហានិភ័យឥណទាន..........១៦
២.៣.៥ ទ្រឹស្តីហានិភ័យឥណទាន..........១៦

## ជំពូកទី៣
## ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ

៣.១ ស្ថានភាពទូទៅរបស់ធនាគារ សហពាណិជ្ជ ក.អ..........១៨
៣.១.១ ប្រវត្តិរបស់ធនាគារ សហពាណិជ្ជ ក.អ..........១៨
៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ធនាគារ សហពាណិជ្ជ ក.អ..........១៩
ក. ចក្ខុវិស័យ..........១៩
ខ. បេសកកម្ម..........១៩
គ. គោលដៅ..........១៩
៣.១.៣ រចនាសម្ព័ន្ធរបស់ធនាគារសហពាណិជ្ជ ក.អ..........២០
៣.២ ដំណើរការក្នុងការផ្តល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក.អ..........២០
៣.២.១ ប្រភេទនៃឥណទាន..........២០
៣.២.២ នីតិវិធីក្នុងការផ្តល់ឥណទាន..........២៤
៣.៣ នីតិវិធីក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព..........២៧
៣.៣.១ គណៈកម្មការគ្រប់គ្រងហានិភ័យ..........២៨
៣.៣.២ វាស់វែងហានិភ័យឥណទាន..........២៩
៣.៣.៣ គ្រប់គ្រងកម្រិតហានិភ័យ នឹងគោលការណ៍បន្ថយហានិភ័យ(CEL)..........៣០
៣.៣.៤ គុណភាពឥណទានទ្រព្យសកម្ម..........៣១

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង..........៣៣
៤.២ ការវិភាគលើចំណុចខ្សោយ..........៣៣

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ........................................................................................ ៣៥
៥.២ ការផ្តល់អនុសាសន៍ ........................................................................................ ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់បណ្តាប្រទេសទាំងអស់នៅក្នុងសកលលោកមិនថាប្រទេសអភិវឌ្ឍក្តី ឬកំពុងអភិវឌ្ឍក្តីសុទ្ធតែមានការចូលរួមយ៉ាងសំខាន់ ពីវិស័យធនាគារក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យមានភាពរីកចម្រើនទៅមុខ ជាលំដាប់ ដោយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុ ងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទូទាំងប្រទេស។ យ៉ាងណាមិញនៅពីក្រោយភាពរីកចម្រើនរបស់សង្គមជាតិ តែងតែមាននូវវត្តមានរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការចូលរួមជ្រោមជ្រែងលើគ្រប់វិស័យ។ តាមស្ថានភាពនាពេលបច្ចុប្បន្ន កម្ពុជាគឺជាប្រទេសដែលមានទីផ្សារសេរី ដោយសារតែកត្តានេះហើយ ទើបធ្វើឱ្យមានការកើនឡើងនូវវិនិយោគគិនជាតិនិងអន្តរជាតិចូលមកវិនិយោគកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ទន្ទឹមនឹងការរីកចម្រើននេះផងដែរយើងក៏មើលឃើញនូវឱកាសការងារ នឹងភាពងាយស្រួលរបស់ប្រជាជនក្នុងការប្រកបការងារអាជីវកម្មបានជាច្រើនវិស័យរួមមាន ធនាគារ ហិរញ្ញវត្ថុ អចលនទ្រព្យ ទេសចរណ៍ ម្ហូបអាហារ បដិសណ្ឋារកិច្ច វាយនភ័ណ្ឌកសិកម្ម ឧស្សាហកម្ម និងសំណង់...។ល។

បើយើងក្រឡេកទៅមើល វិស័យធនាគារនាពេលបច្ចុប្បន្នយើងនឹងឃើញពីប្រភេទនៃផលិតផលឥណទានជាច្រើនដូចជា ឥណទានអាជីវកម្ម ឥណទានប្រើប្រាស់ ឥណទានសម្រាប់ទិញផ្ទះ ឥណទានកសិកម្ម និងឥណទានសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ។ ស្របពេលជាមួយគ្នានេះផងដែរ ធនាគារបានផ្តល់នូវឱកាសដល់សាធារណជនដែលមានបំណងក្នុងការចាប់ផ្តើម នឹងពង្រីកអាជីវកម្មរបស់ខ្លួនតាមរយៈការផ្តល់នូវសេវាឥណទាននិងការប្រឹក្សាយោបល់ជាមួយអ្នកជំនាញដើម្បីកាត់បន្ថយនូវហានិភ័យដែលកើតមាននៅក្នុងប្រតិបត្តិការអាជីវកម្ម។ ម្យ៉ាងវិញទៀត បើសិនជាយើងពឹងផ្អែកទៅលើទុនដែលមានស្រាប់ ឬសាច់ប្រាក់សន្សំដែលមានក្នុងដៃ យើងទទួលស្គាល់ថាការប្រកបអាជីវកម្មរបស់យើងពុំសូវមានហានិភ័យក៏ពិតមែន ប៉ុន្តែក៏ពុំសូវមានភាពរីកចម្រើនផងដែរ។ ជាក់ស្តែង នៅពេលដែលយើងជួបប្រទះនូវហានិភ័យណាមួយយើងពុំមានទុនគ្រប់គ្រាន់សម្រាប់បង្វិលក្នុងការរ៉ាប់រងរាល់ចំណាយផ្សេងៗ អំឡុងពេលអាជីវកម្មខាតបង់នោះទេ។ ហេតុនេះហើយទើបធ្វើឱ្យធនាគារក៏ដូចជា គ្រឹះស្ថានហិរញ្ញវត្ថុឈានជើងចូលមក ដើម្បីជួយដោះស្រាយបញ្ហាជូនដល់សាធារណជន តាមរយៈការផ្តល់ឥណទាននិងការប្រឹក្សាយោបល់។បន្ថែមពីនេះទៀតធនាគារក៏ទទួលបានប្រាក់ចំណេញពីយើងតាមរយៈអត្រាការប្រាក់ ហើយយើងក៏អាចបន្តពង្រីកអាជីវកម្មរបស់ខ្លួនបានផងដែរ។ ទន្ទឹមនឹងនេះ ធនាគារព្រមទាំងយើង ក៏បានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

យោងតាមស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន យើងបានឃើញពីសក្តានុពលរបស់ធនាគារក្នុងការចូលរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើនទៅមុខ តាមរយៈការជំរុញឱ្យមានការកើនឡើងគ្រប់ប្រភេទនៃអាជីវកម្ម នឹងការវិនិយោគទៅលើគ្រប់វិស័យ។ លើសពីនេះទៀត ក៏បានចូលរួមក្នុងការបង្កើននូវឱកាសការងារនៅក្នុងសង្គម ដើម្បីជួយកាត់បន្ថយនូវភាពគ្មានការងារធ្វើ នឹងអត្រានៃអ្នកចំណាកស្រុកនៅក្នុងសង្គមជាតិយើងផងដែរ។ ដោយសារកត្តាសំខាន់ៗខាងលើនេះហើយ ទើបធ្វើឱ្យក្រុមយើងខ្ញុំជ្រើសរើសយកធនាគារ

សហពាណិជ្ជ ក.អ មកធ្វើការសិក្សាស្រាវជ្រាវ នឹងរៀបចំជារបាយការណ៍មួយក្រោមប្រធានបទ " ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ "។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍដូច្នេះទើបត្រូវការ ចូលរួមដ៏សំខាន់ពីសំណាក់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការលើកស្ទួយនូវជីវភាពរស់នៅឱ្យមានភាពប្រសើរឡើង ព្រមទាំងទ្រទ្រង់នូវវិស័យហិរញ្ញវត្ថុឱ្យមានស្ថេរភាពដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពតាមរយៈការប្រមូលផ្តុំនូវធនធានដែលមានក្នុងសេដ្ឋកិច្ចយកមកប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យឯកជន ការបង្កើតការងារក៏ដូចជាការវិនិយោគផ្ទាល់ពីបរទេស។ ដូច្នេះហើយទើបក្រុមយើងខ្ញុំធ្វើការចោទនូវសំណួរពីរ ដែលសំណួរទាំងនេះសុទ្ធតែជាចំណុចសំខាន់នៅក្នុងប្រធានបទរួមមាន៖

១. តើធនាគារ សហពាណិជ្ជ ក.អ មាននីតិវិធីដូចម្តេចក្នុងការផ្តល់ឥណទាន?

២. តើធនាគារ សហពាណិជ្ជ ក.អ មានយុទ្ធសាស្ត្របែបណាក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ធនាគារសហពាណិជ្ជ ក.អ គឺជាធនាគារមួយដែលមានអាយុកាលយូរមកហើយ ដូចនេះគោលបំណងដែលក្រុមយើងខ្ញុំត្រូវសិក្សាពេលនេះផ្តោតទៅលើចំណុចមួយចំនួនដូចជា៖

- ស្វែងយល់ពីដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារឱ្យបានកាន់តែស៊ីជម្រៅ
- ស្វែងយល់ពីយុទ្ធសាស្ត្រនៃដំណើរការផ្តល់ឥណទានប្រកបដោយប្រសិទ្ធភាពខ្ពស់
- ស្វែងយល់ពីលក្ខណសម្បត្តិរបស់អតិថិជនដែលអាចទទួលបានឥណទាន
- ស្វែងយល់ពីភាពខ្លាំង និងភាពខ្សោយរបស់ធនាគារ សហពាណិជ្ជក.អ
- ស្វែងយល់អំពីដំណើរការ នឹងបញ្ហានៃការស្រាវជ្រាវ
- យល់ដឹងអំពីសារៈសំខាន់នៃការផ្តល់ឥណទាន

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

សព្វថ្ងៃធនាគារ សហពាណិជ្ជ ក.អ បាននឹងកំពុងពង្រីកនូវប្រតិបត្តិការអាជីវកម្មរបស់ខ្លួនគ្របដណ្តប់គ្រប់ខេត្ត-រាជធានី ក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះក៏មានបម្រើជូននូវសេវាកម្មសំខាន់ៗដូចជាសេវាទទួលប្រាក់បញ្ញើ សេវាឥណទាន និងសេវាទូទាត់ដែលជាហេតុនាំឱ្យក្រុមយើងខ្ញុំសម្រេចលើកយកនូវដំណើរការនៃការផ្តល់ឥណទានខ្នាតតូចនិងមធ្យមរបស់ធនាគារ សហពាណិជ្ជ ក.អ សាខាអាំងទែកុងទីណាំងតាល់លេខ២៧២-២៧៦ មហាវិថីម៉ៅសេទុង ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញដើម្បីយកមកធ្វើការបង្ហាញតែម្តង។

### ១.៤.២ វិសាលភាព

យើងដឹងហើយថាធនាគារ សហពាណិជ្ជ ក.អ បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដែលមានព័ត៌មានជាច្រើនដែលទាក់ទងទៅនឹងធនាគារ។ ដោយសារតែពេលវេលាមានកំណត់ដើម្បីឆ្លើយតបទៅនឹងគោលបំណង

នៃការស្រាវជ្រាវខាងលើ ដូចនេះក្រុមយើងខ្ញុំសូមលើកយកប្រតិបត្តិការរបស់ធនាគារសហពាណិជ្ជ ក.អ ដែលស្ថិតនៅក្នុងឆ្នាំ ២០២៣ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវលទ្ធផលនៃការសិក្សាស្រាវជ្រាវ នៅក្នុងការសរសេរនិក្ខេបបទនេះក្រុមយើងខ្ញុំបានប្រើតាមវិធីសាស្ត្រគុណវិស័យ (Qualitative Method) ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារដែលបានមកពីធនាគារ សហពាណិជ្ជ ក.អ ដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគនឹងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ អំពីប្រសិទ្ធភាពនៃដំណើរការផ្តល់ឥណទានរបស់ធនាគារ ដើម្បីធ្វើការបកស្រាយ។

សម្រាប់សំណួរទី១ ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ (Qualitative Research) ដោយផ្តោតសំខាន់ទៅលើគេហទំព័រ។ ចំពោះប្រភពទាំងនោះរួមមានដូចជាឯកសាររបស់ក្រុមហ៊ុន សហពាណិជ្ជ ក.អ ផ្ទាល់ គេហទំព័ររបស់ធនាគារសហពាណិជ្ជ ក.អ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត ថែមទាំងមានការសាកសួរព័ត៌មាន ការសម្ភាសន៍ទៅលើប្រធានក្រុមរបស់ធនាគារដោយផ្ទាល់ថែមទៀតផង។

សម្រាប់សំណួរទី២ ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ (Qualitative Research) ដោយផ្តោតសំខាន់ទៅលើគេហទំព័រ។ ចំពោះប្រភពទាំងនោះរួមមានដូចជាឯកសារផ្សេងៗនៅក្នុងបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា វេបសាយផ្សេងៗ ព្រមទាំងឯកសារមួយចំនួនទៀត បានមកពីការសាកសួរព័ត៌មាន ពីប្រធានក្រុមរបស់ធនាគារ នឹងសុំការផ្តល់មតិយោបល់ ការណែនាំពីអ្នកគ្រូដឹកនាំការស្រាវជ្រាវ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនីមួយៗ សុទ្ធសឹងតែទទួលបាននូវសារៈសំខាន់ដោយឡែកពីគ្នា ទៅតាមវិធីសាស្ត្រក៏ដូចជាលក្ខណៈខុសគ្នារបស់ប្រធានបទ។ ជាក់ស្តែងក្នុងការសិក្សាទៅលើប្រធានបទនេះ យើងទទួលបាននូវសារៈសំខាន់ដូចជា៖

### ក. សារៈសំខាន់ដែលយើងខ្ញុំទទួលបានរួមមាន៖

- ទទួលបាននូវចំណេះដឹង ការអនុវត្តជាក់ស្តែង នឹង ទ្រឹស្តី
- ពង្រីកចំណេះដឹងផ្ទាល់ខ្លួន
- យល់ដឹងអំពីស្ថានភាពទូទៅរបស់ធនាគារសហពាណិជ្ជ
- យល់ដឹងស៊ីជម្រៅអំពីដំណើរការនៃការផ្តល់ឥណទាន
- ជាស្នាដៃដើម្បីបន្សល់ទុកជាឯកសារដល់និស្សិត ឬអ្នកស្រាវជ្រាវជំនាន់ក្រោយៗ
- យល់ដឹងអំពីផលប្រយោជន៍នៃការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជ
- យល់ដឹងអំពីនីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារពាណិជ្ជ
- យល់ដឹងអំពីវិធីសាស្ត្រក្នុងការទប់ស្កាត់ហានិភ័យឥណទាន ដើម្បីទប់ស្កាត់ការខាតបង់នានា។

**ខ. សារៈសំខាន់ដែលធនាគារទទួលបាន រួមមាន៖**

- យល់ដឹងអំពីចំណុចខ្វះខាតរបស់ធនាគារ
- កែលម្អចំណុចខ្វះខាតដែលបានមកពីការផ្តល់អនុសាសន៍
- បង្ហាញអោយសាធារណជនយល់ដឹងពីប្រភេទឥណទានរបស់ធនាគារ
- បង្ហាញដល់និយោជិកដែលចង់វិនិយោគអោយស្គាល់ធនាគារកាន់តែច្បាស់
- បង្ហាញពីកេរ្តិ៍ឈ្មោះល្អទូទាំងប្រទេស និងអន្តជាតិ

**គ. សារៈសំខាន់ដែលសង្គមជាតិទទួលបាន រួមមាន៖**

- ធ្វើឱ្យប្រទេសជាតិសម្បូរទៅដោយធនធានមនុស្ស ក្នុងកិច្ចការស្រាវជ្រាវលើវិស័យធនាគារ
- ប្រទេសមានភាពរីកចម្រើន ព្រោះសាធារណជនមានការយល់ដឹងកាន់តែស៊ីជម្រៅលើវិស័យធនាគារ ជាពិសេសទាក់ទងនឹងការទទួលឥណទានពីធនាគារ ការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធភាព
- សាធារណជនកាន់តែមានចំណេះដឹងទាក់ទងនឹងការទទួលឥណទាន កាត់បន្ថយហានិភ័យ
-ជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋព្រោះ ពួកគាត់ប្រើប្រាស់ឥណទានចំគោលដៅកាត់បន្ថយហានិភ័យ នឹងបំណុលវ៉ែនក។
-ជួយសេដ្ឋកិច្ចមានភាពរីកចម្រើន ព្រោះឥណទានអាចធ្វើឱ្យអាជីវកម្ម ក្នុងការវិនិយោគលើគម្រោងថ្មីដែលអាចនាំឱ្យមានការងារកាន់តែច្រើន ផលិតកម្មកាន់តែខ្ពស់ ការច្នៃប្រឌិតកាន់តែច្រើនឡើងថែមទៀត។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី១ សេចក្តីផ្តើម៖ គឺជាការបង្ហាញអំពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវគោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ នឹងសារៈសំខាន់នៃការស្រាវជ្រាវ។

ជំពូកទី២ រំលឹកទ្រឹស្តី៖ គឺជាការបង្ហាញអំពីលក្ខណៈទូទៅនៃការផ្តល់ឥណទាន និងការបញ្ចៀសនូវហានិភ័យ ដែលកើតមានឡើងរួមជាមួយនឹងការបកស្រាយដែលទាក់ទងនឹងបញ្ហាដែលបានចោទសួរ។

ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖ គឺជាការបង្ហាញពីស្ថានភាពទូទៅរបស់ធនាគារ សហពាណិជ្ជក.អ ដែលរួមមានប្រវត្តិរបស់ធនាគារ និមិត្តសញ្ញា រចនាសម្ព័ន្ធ គោលនយោបាយ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង ទស្សនវិស័យ បេសកកម្ម នឹងលទ្ធផលដែលទាក់ទងនឹងសំណួរដែលបានចោទសួរ។

ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖ គឺជាការវិភាគលើគ្រប់ចំណុចទាំងអស់ដោយធ្វើការអភិវឌ្ឍនូវចំណុចខ្លាំងរបស់ខ្លួន នឹងធ្វើការកែលម្អនូវចំណុចខ្វះខាតដែលកើតមានឡើងក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖ គឺជាការបង្ហាញនូវការសន្និដ្ឋានគ្រប់ជ្រុងជ្រោយទាំងអស់មិនថាចំណុចខ្លាំង ឬចំណុចខ្សោយ ព្រមទាំងការផ្តល់នូវអនុសាសន៍ទៅលើចំណុចខ្សោយក្នុងការកែលម្អផងដែរ។

# ជំពូកទី២

# ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃដំណើរការក្នុងការផ្តល់ឥណទានរបស់ធនាគារ

### ២.១.១ និយមន័យដំណើរការ

ដំណើរការ សំដៅដល់ការអនុវត្តនូវប្រតិបត្តិការដែលកំណត់ទុកជាមុនតាមលំដាប់បន្តគ្នាលើទិន្នន័យបញ្ចូលគ្នាដើម្បីបញ្ចេញជាទិន្នន័យ ឬព័ត៌មាន[1]។

ដំណើរការ (Process) គឺជាសមីការនៃសកម្មភាព ឬជំហានដែលត្រូវអនុវត្តប្រកបដោយលំដាប់នឹងមានគោលបំណងដើម្បីសម្រេចបាននូវលទ្ធផលកំណត់។ឧទាហរណ៍ដំណើរការអាចជាការប្រមូលផលិតផលឬការផ្តល់សេវាកម្មណាមួយ ដែលត្រូវការជំហានបន្ថែមនៅក្នុងការងារចម្រុះផ្សេងៗគ្នា ដើម្បីឱ្យសម្រេចបានការងារពេញលេញ។

### ២.១.២ ប្រវត្តិនៃដំណើរការ

ប្រវត្តិនៃ "ដំណើរការ" មានភាពរីកចម្រើនពីកម្រិតប្រតិបត្តិការសាមញ្ញ ទៅជាការអភិវឌ្ឍប្រព័ន្ធដំណើរការស្មុគស្មាញក្នុងវិស័យនានា។ ប្រវត្តិនេះ អាចត្រូវបានចែកចេញជាចំណុចសំខាន់ៗដូចខាងក្រោមៈ

**១. សង្គមដើម និងការប្រតិបត្តិការសាមញ្ញ:**

ក្នុងអំឡុងពេលដើម មនុស្សត្រូវការប្រើប្រាស់ប្រតិបត្តិការការងារដែលសាមញ្ញដូចជា ចាប់ផ្តើមប្រើប្រាស់ឧបករណ៍កសិកម្ម ឬប្រមូលផលក្នុងវិស័យកសិកម្ម។

**២. ការអភិវឌ្ឍពាណិជ្ជកម្ម និងសេដ្ឋកិច្ច:**

ក្នុងកំឡុងសម័យ វិស័យឧស្សាហកម្មមានការអភិវឌ្ឍឡើង ដំណើរការផលិតក៏មានភាពរីកចម្រើនផងដែរ។ ប្រព័ន្ធនៃការកែច្នៃផលិតផលឧស្សាហកម្មនឹងជំហានផ្សេងៗទៀតដើម្បីបង្កើតផលិតផលប្រសើរ។

**៣. ការបង្កើតវិស័យគ្រប់គ្រង:**

នៅក្នុងសតវត្សទី ២០ និង ២១ ការអភិវឌ្ឍបច្ចេកវិទ្យាបានជំរុញការរចនានឹងប្រើប្រាស់ប្រព័ន្ធដំណើរការដែលមានភាពស្មុគស្មាញខ្ពស់ជាងមុន ដូចជា ប្រព័ន្ធកុំព្យូទ័រ នឹង កម្មវិធីគ្រប់គ្រងដើម្បីសម្រេចបំណង។

**៤. ដំណើរការដែលត្រូវបានប្រើប្រាស់ក្នុងវិស័យជាច្រើន:**

បច្ចុប្បន្ននេះ "ដំណើរការ" ត្រូវបានប្រើប្រាស់ក្នុងវិស័យជាច្រើនដូចជា ការផលិត សេវាកម្ម នឹងអង្គការអាជីវកម្មទាំងមូល។ វាគឺជាការអនុវត្តដែលមានលំដាប់ នឹងធ្វើឱ្យមានប្រសិទ្ធភាពក្នុងការកសាងផលិតភាពនឹងភាពរីកចម្រើននៅក្នុងអង្គការនោះ។

ប្រវត្តិនៃដំណើរការបានប្រើប្រាស់គ្រប់គ្រងសកម្មភាពនៅក្នុងអង្គការផ្សេងៗ ហើយបច្ចុប្បន្នមានការប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយដើម្បីធ្វើឱ្យដំណើរការទាំងអស់មានប្រសិទ្ធភាពខ្ពស់ នឹងប្រើធនធានតិចជាងមុន។

### ២.១.៣ ប្រភេទនៃដំណើរការ

មានដំណើរការជាច្រើនប្រភេទ ហើយការចាត់ថ្នាក់ជាក់លាក់អាស្រ័យលើបរិបទ។ ជាទូទៅដំណើរការអាចត្រូវបានចាត់ថ្នាក់ទៅជាធម្មជាតិ (ដូចជាវដ្តទឹក) នឹងផលិតដោយមនុស្ស (ដូចជាការផលិត) ឬតាម

[1] Process model. Scott Baird (2024). *"What is Process?"*: https://www.processmodel.com/blog/what-is-a-process/

គោលបំណងរបស់វា (ដូចជាប្រតិបត្តិការ ការគ្រប់គ្រង ឬយុទ្ធសាស្ត្រក្នុងអាជីវកម្ម)។ នៅក្នុងការផលិត មានប្រភេទផ្សេងៗគ្នាដូចជា បន្ត ដាច់ពីគ្នា ច្រំដែល ក្នុងចំណោមផលិតផលផ្សេងទៀត[2]។

**១. រចនាសម្ព័ន្ធដំណើរការ (Structured Process)៖** សម្ព័ន្ធដំណើរការ អាចជាដំណើរការផលិតកម្ម ផលិតផល និងសេវាកម្ម។ ដំណើរការនៃការជួបប្រជុំគ្នាគឺជាឧទាហរណ៍ដ៏ល្អមួយ។ មិនមែនដំណើរការផលិតកម្មទាំងអស់ត្រូវបានរៀបចំឡើងនោះទេ ប៉ុន្តែមានទំនោរក្នុងការធ្វើឱ្យពួកវាមានរចនាសម្ព័ន្ធតាមដែលអាចធ្វើទៅបាន។

**២.ដំណើរការប្រភេទករណី (Case-type Process)៖** ដំណើរការនេះប្រហែលជាត្រូវដោះស្រាយជាមួយនឹងស្ថានភាពជាច្រើននៅក្នុងពិភពពិត។ វាត្រូវតែសម្របខ្លួនជាបន្តបន្ទាប់ ដំណើរការនេះអាចពឹងផ្អែកលើធាតុចូលផ្សេងៗនៃបរិស្ថានរបស់វា ហើយប្រព័ន្ធ ឬអ្នកដែលប្រតិបត្តិដំណើរការនេះមិនមានការគ្រប់គ្រងលើពេលណា នឹងអ្វីដែលពួកគេនឹងទទួលបាន។ តួអង្គខាងក្រៅដែលមានអាកប្បកិរិយាមិនអាចទាយទុកជាមុនបាន ពួកគេមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រព័ន្ធទេ។

**៣.ដំណើរការស្រាវជ្រាវ (Research Process)៖** ដំណើរការស្រាវជ្រាវមិនបង្កើតអ្វីថ្មីទេ។ វាគឺចង់រៀនពីអ្វីដែលមាន។ វាមិនមែនជាវិធីសាស្ត្រវិស្វកម្មទេ ទោះបីជាវាអាចបង្កប់ នឹងប្រើវិធីសាស្ត្រវិស្វកម្មដើម្បីបង្កើតការពិសោធន៍ថ្មីៗក៏ដោយ ឬវាអាចត្រូវបានបង្កប់នៅក្នុងវិធីសាស្ត្រវិស្វកម្ម[3]។

**៤.ដំណើរការស្នូល (Core Processes)៖** របៀបដែលអ្នកផ្តល់តម្លៃដើម្បីកំណត់អត្តសញ្ញាណដំណើរការស្នូល សូមសួរខ្លួនឯងថា "តើអាជីវកម្មរបស់ខ្ញុំបង្កើតតម្លៃ នឹងរកប្រាក់ចំណូលបានដោយរបៀបណា?" ដំណើរការស្នូលត្រូវបានគេស្គាល់ថាជាដំណើរការចម្បង ដូច្នេះវិធីមួយផ្សេងទៀតក្នុងការមើលវាគឺសួរថា "តើអាជីវកម្មរបស់ខ្ញុំធ្វើអ្វីជាចម្បង?"

**៥.ដំណើរការគាំទ្រ (Supporting Processes)៖** ធ្វើឱ្យការដឹកជញ្ជូនតម្លៃអាចធ្វើទៅបាននៅលើផ្ទៃខាងលើ វាអាចហាក់ដូចជាមានភាពខុសគ្នាដ៏ល្អរវាងការបង្កើតតម្លៃ និងការបង្កើតតម្លៃ ប៉ុន្តែមានពិភពនៃភាពខុសគ្នារវាងគំនិតទាំងពីរ។ដំណើរការស្នូលបម្រើអតិថិជនខាងក្រៅដោយផ្ទាល់នឹងបង្កើតប្រាក់ចំណូល។ ដំណើរការគាំទ្របម្រើដល់"អតិថិជន" ខាងក្នុងហើយមិនបានបង្កើតប្រាក់ចំណូលនៅក្នុងខ្លួនរបស់ពួកគេទេ។

**៦.ដំណើរការគ្រប់គ្រង (Management Processes)៖** ដំណើរការទាំងឡាយ ទោះជាដំណើរការស្នូល ឬជាដំណើរការគាំទ្រ ទាមទារឱ្យមានផែនការ ការសម្របសម្រួល ការត្រួតពិនិត្យ និងការគ្រប់គ្រង។ ដំណើរការគ្រប់គ្រងក៏រួមបញ្ចូលផងដែរនូវការវាស់វែងលទ្ធផលរួម ការដោះស្រាយជាមួយឱកាស និងការគំរាមកំហែងដែលអាចជួយ ឬធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មរបស់អ្នក។ វាក៏អាស្រ័យលើការគ្រប់គ្រងដើម្បីធានាថាតម្រូវការនៃការអនុលោមតាមបទប្បញ្ញត្តិត្រូវបានបំពេញ ហើយគោលដៅហិរញ្ញវត្ថុ នឹងថវិកាត្រូវបានបំពេញ។ ទោះបីជាដំណើរការគ្រប់គ្រងមិនបង្កើតប្រាក់ចំណូលដោយផ្ទាល់ក៏ដោយពួកវាបង្កើនប្រសិទ្ធភាពនៃការបង្កើតប្រាក់ចំណូល នឹងធានាឱ្យមានការបន្តរស់រានមានជីវិតនៃអាជីវកម្មទាំងមូល[4]។

---

[2] Eyelit Technologies. (2021, May 5). *What are type of Process?* Retrieved March, 02 2025 from https://www.google.com/search?q=what+are+type+of+process

[3] Axel Vanhooren. (2021, June 17). *Type of Process.* Retrieved March, 02 2025 from https://www.linkedin.com/pulse/five-types-processes-axel-vanhooren

[4] *Amit Kothari.* (2025, April 20). *What are type of Business Process Exists.* Retrieved March, 02 2025 from https://tallyfy.com/types-of-business-processes/

**២.១.៤ និយមន័យនៃធនាគារ**

ធនាគារត្រូវបានគេឱ្យនិយមន័យជាច្រើនដូចជា៖

- ធនាគារ៖ គឺជាពាក្យដែលមនុស្សប្រើយ៉ាងទូលំទូលាយដើម្បីសំដៅទៅលើប្រភេទផ្សេងៗនៃស្ថាប័នហិរញ្ញវត្ថុ។ អ្វីដែលអ្នកគិតថាជា "ធនាគារ" របស់អ្នកអាចជាធនាគារ នឹងក្រុមហ៊ុនជឿទុកចិត្ត ធនាគារសន្សំ សមាគមសន្សំ នឹងកម្ចី ឬស្ថាប័នដាក់ប្រាក់ផ្សេងទៀត។

- ធនាគារ៖ គឺជាស្ថាប័នឯកជន ដែលជាទូទៅទទួលយកប្រាក់បញ្ញើ នឹងផ្តល់ប្រាក់កម្ចី។ ប្រាក់បញ្ញើគឺជាប្រាក់ដែលមនុស្សទុកនៅក្នុងស្ថាប័នមួយដោយយល់ថាពួកគេអាចយកវាមកវិញនៅពេលណាក៏បាន ឬនៅពេលអនាគតតាមការព្រមព្រៀង។ ប្រាក់កម្ចី គឺជាលុយដែលទុកអោយអ្នកខ្ចី ជាទូទៅត្រូវសងវិញដោយការប្រាក់។ សកម្មភាពនៃការទទួលប្រាក់បញ្ញើ និងការផ្តល់ប្រាក់កម្ចីត្រូវបានគេហៅថាអន្តរការីហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយ អាជីវកម្មរបស់ធនាគារមិនបានបញ្ចប់នៅទីនោះទេ។ មនុស្ស នឹងអាជីវកម្មភាគច្រើនបង់វិក្កយបត្ររបស់ពួកគេដោយប្រើគណនីត្រួតពិនិត្យធនាគារ ដោយដាក់ធនាគារនៅចំកណ្តាលនៃប្រព័ន្ធទូទាត់របស់យើង។ ធនាគារ គឺជាប្រភពដ៏សំខាន់នៃប្រាក់កម្ចីអ្នកប្រើប្រាស់ ប្រាក់កម្ចីសម្រាប់រថយន្ត ផ្ទះ ការអប់រំ ក៏ដូចជាអ្នកផ្តល់ប្រាក់កម្ចីសំខាន់ៗដល់អាជីវកម្ម ជាពិសេសអាជីវកម្មខ្នាតតូច។ ធនាគារត្រូវបានពិពណ៌នាជាញឹកញាប់ថាជាម៉ាស៊ីនសេដ្ឋកិច្ចរបស់យើង មួយផ្នែកដោយសារតែមុខងារទាំងនេះ ប៉ុន្តែក៏ដោយសារតែតួនាទីសំខាន់ៗរបស់ធនាគារដើរតួជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាលផងដែរ[5]។

- ធនាគារ៖ គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលផលិតនឹងលក់មូលធនជាសាធារណៈប្រកបទៅដោយវិជ្ជាជីវៈ ហើយបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម[6]។

**២.១.៥ ប្រវត្តិនៃធនាគារ**

ប្រវត្តិសាស្ត្រនៃធនាគារបានចាប់ផ្តើមជាមួយនឹងធនាគារគំរូដំបូង ពោលគឺពាណិជ្ជករនៃពិភពលោកដែលបានផ្តល់ប្រាក់កម្ចីគ្រាប់ធញ្ញជាតិដល់កសិករ និងពាណិជ្ជករដែលដឹកជញ្ជូនទំនិញរវាងទីក្រុង។ នេះគឺប្រហែលឆ្នាំ២០០០ មុនគ.ស នៅអាសេរី ឥណ្ឌា និងស៊ូមីរ។ ក្រោយមកនៅប្រទេសក្រិចបុរាណនឹងក្នុងកំឡុងចក្រភពរ៉ូម អ្នកផ្តល់ប្រាក់កម្ចីដែលមានមូលដ្ឋាននៅប្រាសាទនានាបានផ្តល់ប្រាក់កម្ចី ខណៈពេលដែលទទួលយកប្រាក់បញ្ញើនឹងធ្វើការផ្លាស់ប្តូរប្រាក់។ បុរាណវិទ្យាពីសម័យកាលនេះនៅក្នុងប្រទេសចិនបុរាណ និងឥណ្ឌាក៏បានបង្ហាញភស្តុតាងនៃការខ្ចីប្រាក់ផងដែរ។ គ្រួសារ Bardi និង Peruzzi បានគ្រប់គ្រងធនាគារនៅ Florence សតវត្សទី១៤ ដោយបានបង្កើតសាខានៅក្នុងតំបន់ជាច្រើនទៀតនៃទ្វីបអឺរ៉ុប។

សតវត្សទី ១៥-១៧ ការពង្រីកប្រទេសអ៊ីតាលីនៅចន្លោះឆ្នាំ ១៥២៧ និង ១៥៧២ ក្រុមគ្រួសារធនាគារសំខាន់ៗមួយចំនួនបានកើតចេញពីសាធារណរដ្ឋ Genoese នៅភាគខាងជើងប្រទេសអ៊ីតាលី ដូចជាគ្រួសារ Grimaldi, Spinola និង Pallavicino ដែលមានឥទ្ធិពល។ អេស្ប៉ាញ និងចក្រភពអូតូម៉ង់នៅឆ្នាំ ១៤០១ ចៅក្រមនៃទីក្រុងបាសេឡូណា បន្ទាប់មកជារដ្ឋធានីនៃ Principality of Catalonia បានបង្កើតឡើងនៅក្នុងទី

[5] CT.gov. (June 5, 2020*). Bank*. Retrieved March, 02 2025 from https://portal.ct.gov/dob/consumer-education/abcs-of-banking---banks-and-our-economy

[6] រៀបរៀងដោយនិស្សិត ប៉ុង ដាលីន, វុទ្ធី ស៊ីវមី, ហាវ តាក់, ឆាយ រដ្ឋា, វ៉ាន់គឹមជូ. (ឆ្នាំ២០២២). *ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យជំនាន់ទី២០. វិទ្យាស្ថានវ៉ាន់ដា. ទំព័រទី៧. ភ្នំពេញ។

ក្រុងដែលការចម្លងគំរូដំបូងនៃការផ្លាស់ប្តូរប្រាក់បញ្ញើ Venetian គឺ Taula de canvi de Barcelona ឬ Table of Exchange ដែលត្រូវបានគេចាត់ទុកថាជាធនាគារសាធារណៈដំបូងគេរបស់អឺរ៉ុប។ ពួកគេបានរីកចម្រើននៅក្នុងទីក្រុងបាកដាដក្នុងកំឡុងសតវត្សទី ១៨ និង ១៩ ក្រោមការគ្រប់គ្រងរបស់អូតូម៉ង់ ដោយអនុវត្តមុខងារពាណិជ្ជកម្មសំខាន់ៗដូចជាការផ្តល់ប្រាក់ នឹងធនាគារ។ ដូចជនជាតិអាមេនីដែរ ជនជាតិយូដាអាចចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មចាំបាច់ ដូចជាការផ្តល់ប្រាក់ នឹងធនាគារ ដែលត្រូវបានផ្តល់ជូនសម្រាប់ជនមូស្លីមក្រោមច្បាប់អ៊ីស្លាម។

សតវត្សទី ១៧-១៩ ការលេចឡើងនៃធនាគារទំនើបនៅចុងបញ្ចប់នៃសតវត្សទី ១៦ ក្នុងកំឡុងសតវត្សទី ១៧ មុខងារធនាគារបែបប្រពៃណីនៃការទទួលយកប្រាក់បញ្ញើ ការផ្តល់ប្រាក់ ការផ្លាស់ប្តូរប្រាក់ និងការផ្ទេរប្រាក់ត្រូវបានរួមបញ្ចូលគ្នាជាមួយនឹងការចេញបំណុលរបស់ធនាគារដែលបម្រើការជំនួសកាក់មាស និងប្រាក់។ ការអនុវត្តធនាគារថ្មីបានលើកកម្ពស់កំណើនពាណិជ្ជកម្ម និងឧស្សាហកម្មដោយផ្តល់នូវមធ្យោបាយទូទាត់ប្រកបដោយសុវត្ថិភាព ងាយស្រួលផ្គត់ផ្គង់ប្រាក់ដែលឆ្លើយតបកាន់តែច្រើនទៅនឹងតម្រូវការពាណិជ្ជកម្ម ក៏ដូចជាតាមរយៈ "ការបញ្ចុះតម្លៃ" បំណុលអាជីវកម្ម។ នៅចុងបញ្ចប់នៃសតវត្សទី១៧ ធនាគារក៏បានក្លាយជារឿងសំខាន់សម្រាប់តម្រូវការមូលនិធិរបស់រដ្ឋអឺរ៉ុបដែលកំពុងប្រយុទ្ធ។នេះនាំឱ្យមានបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងធនាគារកណ្តាលដំបូងគេ។ ភាពជោគជ័យនៃបច្ចេកទេស និងការអនុវត្តធនាគារថ្មីនៅទីក្រុង Amsterdam និងទីក្រុងឡុងដ៍បានជួយផ្សព្វផ្សាយគំនិត នៅកន្លែងផ្សេងទៀតនៅអឺរ៉ុប។

កំឡុងពេលជាប់គាំងនៃឆ្នាំ ១៩២៩ មុនវិបត្តិសេដ្ឋកិច្ចធំ តម្រូវការមានត្រឹមតែ ១០%។ [១៩៨] ម្យ៉ាងវិញទៀតក្រុមហ៊ុនឈ្មួញជើងសានឹងផ្តល់ប្រាក់កម្ចី $9 សម្រាប់រាល់ $1 ដែលវិនិយោគិនបានដាក់ប្រាក់។ នៅពេលដែលទីផ្សារធ្លាក់ចុះ ឈ្មួញកណ្តាលបានហៅប្រាក់កម្ចីទាំងនេះ ដែលមិនអាចសងវិញបាន។ ធនាគារបានចាប់ផ្តើមបរាជ័យ នៅពេលដែលកូនបំណុលបានសងបំណុល ហើយអ្នកដាក់ប្រាក់បញ្ញើបានព្យាយាមដកប្រាក់បញ្ញើរបស់ពួកគេយ៉ាងច្រើន ដែលបង្កឱ្យមានដំណើរការធនាគារជាច្រើន។ ការធានារបស់រដ្ឋាភិបាល និងបទប្បញ្ញត្តិធនាគារ Federal Reserve ដើម្បីទប់ស្កាត់ការភ័យស្លន់ស្លោបែបនេះមិនមានប្រសិទ្ធភាពឬមិនត្រូវបានប្រើប្រាស់។

ការបរាជ័យរបស់ធនាគារនាំឱ្យបាត់បង់ទ្រព្យសម្បត្តិរាប់ពាន់លានដុល្លារ។[១៩៩] បំណុលដែលលើសបានកាន់តែធ្ងន់ព្រោះតម្លៃនិងប្រាក់ចំណូលបានធ្លាក់ចុះ ២០-៥០% ប៉ុន្តែបំណុលនៅតែមានចំនួនប្រាក់ដុល្លារដដែល។ បន្ទាប់ពីការភ័យស្លន់ស្លោក្នុងឆ្នាំ ១៩២៩ ហើយក្នុងអំឡុងពេល ១០ ខែដំបូងនៃឆ្នាំ ១៩៣០ ធនាគារអាមេរិកចំនួន ៧៤៤ បានបរាជ័យ។ នៅខែមេសា ឆ្នាំ ១៩៣៣ ប្រាក់បញ្ញើប្រហែល ៧ ពាន់លានដុល្លារត្រូវបានជាប់គាំងនៅក្នុងធនាគារដែលបរាជ័យ ឬទុកចោលដោយគ្មានអាជ្ញាប័ណ្ណបន្ទាប់ពីថ្ងៃឈប់សម្រាករបស់ធនាគារខែមីនា។

សតវត្សទី ២១ ដើមទសវត្សរ៍ឆ្នាំ ២០០០ ត្រូវបានសម្គាល់ដោយការប្រេបាច់បញ្ចូលគ្នានៃធនាគារដែលមានស្រាប់ នឹងការចូលទៅក្នុងទីផ្សារនៃអន្តរការីហិរញ្ញវត្ថុផ្សេងទៀត៖ ស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ អ្នកលេងសាជីវកម្មធំៗ បានចាប់ផ្តើមស្វែងរកផ្លូវរបស់ពួកគេចូលទៅក្នុងសហគមន៍សេវាកម្មហិរញ្ញវត្ថុដោយផ្តល់ជូននូវការប្រកួតប្រជែងដល់ធនាគារដែលបានបង្កើតឡើង។ សេវាកម្មសំខាន់ៗដែលផ្តល់ជូនរួមមាន ការធានា

វ៉ាប់រង សោធននិវត្តន៍ ទៅវិញទៅមក ទីផ្សារប្រាក់ និងមូលនិធិការពារហានិភ័យ ប្រាក់កម្ចី ឥណទាន និងមូលបត្រ។ ជាការពិតណាស់ នៅចុងឆ្នាំ ២០០១ មូលធននីយកម្មទីផ្សារនៃអ្នកផ្តល់សេវាហិរញ្ញវត្ថុធំជាងគេទាំង ១៥ របស់ពិភពលោក រួមមានធនាគារមិនមែនធនាគារចំនួនបួន។ ទសវត្សរ៍ដំបូងនៃសតវត្សទី ២១ បានឃើញចំណុចកំពូលនៃការច្នៃប្រឌិតបច្ចេកទេសក្នុងវិស័យធនាគារក្នុងរយៈពេល ៣០ ឆ្នាំកន្លងមក ហើយបានឃើញការផ្លាស់ប្តូរដ៏សំខាន់មួយចេញពីធនាគារបែបប្រពៃណីទៅធនាគារតាមអ៊ីនធឺណេត។ ចាប់ផ្តើមនៅឆ្នាំ ២០១៥ ការអភិវឌ្ឍដូចជាធនាគារបើកចំហបានធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់ភាគីទីបីក្នុងការចូលប្រើទិន្នន័យប្រតិបត្តិការធនាគារ ណែនាំ API នឹងគំរូសុវត្ថិភាពស្តង់ដារ។ ដំណើរការនៃការបង្កើតថ្មីផ្នែកហិរញ្ញវត្ថុក៏រីកចម្រើនយ៉ាងខ្លាំងនៅក្នុងប៉ុន្មានទសវត្សរ៍ដំបូងនៃសតវត្សទី ២១ ដោយបង្កើនសារៈសំខាន់ នឹងប្រាក់ចំណេញនៃហិរញ្ញវត្ថុមិនមែនធនាគារ។ ប្រាក់ចំណេញបែបនេះត្រូវបានដាក់កម្រិតជាមុនចំពោះឧស្សាហកម្មមិនមែនធនាគារ បានជំរុញឱ្យការិយាល័យត្រួតពិនិត្យរូបិយប័ណ្ណ (OCC) លើកទឹកចិត្តឱ្យធនាគារស្វែងរកឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ធ្វើពិពិធកម្មអាជីវកម្មរបស់ធនាគារ ក៏ដូចជាការកែលម្អសុខភាពសេដ្ឋកិច្ចធនាគារ។ អាស្រ័យហេតុនេះ ដោយសារឧបករណ៍ហិរញ្ញវត្ថុផ្សេងគ្នាកំពុងត្រូវបានស្វែងយល់ នឹងអនុម័តដោយទាំងឧស្សាហកម្មធនាគារ នឹងមិនមែនធនាគារ ភាពខុសគ្នារវាងស្ថាប័នហិរញ្ញវត្ថុផ្សេងៗគ្នាកំពុងបាត់ទៅវិញបន្តិចម្តងៗ។ ជាឧទាហរណ៍ក្នុងឆ្នាំ ២០២០ OCC បានធ្វើឱ្យមានភាពច្របូកច្របល់ពីភាពខុសគ្នារវាងធនាគារប្រពៃណី នឹងប្រព័ន្ធអេកូគ្រីបតូ នៅពេលដែលវាបានបោះពុម្ពសំបុត្របកស្រាយមួយចំនួនដែលបញ្ជាក់ពីសមត្ថភាពរបស់ធនាគារជាតិក្នុងការគ្រប់គ្រងរូបិយប័ណ្ណគ្រីបតូ នឹងផ្តល់សេវាកម្មធនាគារដល់ក្រុមហ៊ុនរូបិយប័ណ្ណគ្រីបតូ ក៏ដូចជាប្រើប្រាស់ការច្នៃប្រឌិត blockchain ដូចជា កាក់ស្ថេរភាពជាហេដ្ឋារចនាសម្ព័ន្ធទូទាត់។ លើសពីនេះទៀតនៅឆ្នាំ ២០២១ OCC បានផ្តល់ធម្មនុញ្ញធនាគារសហព័ន្ធដំបូងរបស់ខ្លួនដល់ Anchorage Digital ដែលជាវេទិកាទ្រព្យសកម្មឌីជីថលសម្រាប់ស្ថាប័ននានា[7]។

## ២.២ នីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារ

### ២.២.១ និយមន័យឥណទាន

- ឥណទាន គឺជាការផ្តល់ប្រាក់ឬទ្រព្យសម្បត្តិដល់អ្នកខ្ចីដោយមានលក្ខខណ្ឌដាក់លាក់សម្រាប់ការសងត្រលប់មកវិញ។ នៅទីនេះ មាននិយមន័យនៃឥណទានពីប្រភពផ្សេងៗ៖

- ឥណទាន: គឺជាការឱ្យអតិថិជនខ្ចីប្រាក់ ដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗរបស់ពួកគេ ហើយអតិថិជនមានកាតព្វកិច្ចសងត្រលប់មកវិញនូវប្រាក់ដើម ការប្រាក់ នឹងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត។

- ឥណទាន: គឺជាចំនួនទឹកប្រាក់ដែលមានកាតព្វកិច្ចជាក់លាក់នៃការសង។ ប្រភេទនៃឥណទានរួមមាន៖ ប្រាក់កម្ចី ឥណទានពាណិជ្ជកម្ម សញ្ញាប័ណ្ណ វិក្កយបត្រ នឹងកិច្ចព្រមព្រៀងផ្សេងទៀតដែលត្រូវសងក្នុងរយៈពេលមួយ។

[7] WIKIPEDIA. Last Edit. (2025, April 21). *History of Banking* Retrieved March, 05 2025 from https://en.wikipedia.org/wiki/History_of_banking#References

- ឥណទាន: គឺជាដែនកំណត់ដែលបានកំណត់ជាមុនដោយអ្នកឱ្យខ្ចី ដែលបង្ហាញពីចំនួនអតិបរមាដែលអ្នកខ្ចីអាចទទួលបានសម្រាប់កម្ចី ឬឥណទាន។ វាផ្តល់នូវភាពបត់បែន ដែលអនុញ្ញាតឱ្យអ្នកខ្ចីទាញយកមូលនិធិរហូតដល់ដែនកំណត់ដែលបានបញ្ជាក់តាមតម្រូវការ។

- ឥណទាន: គឺជាការឱ្យខ្ចីប្រាក់ដែលមានចងជាកិច្ចសន្យាត្រឹមត្រូវ ហើយអ្នកខ្ចីប្រាក់មានកាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីអោយបានស្របច្បាប់ នឹងសងត្រលប់មកវិញនូវប្រាក់ដើម ការប្រាក់ នឹងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដែលមានចែងក្នុងកិច្ចសន្យាឱ្យបានទៀងទាត់[8]។

- ឥណទាន: គឺជាកិច្ចសន្យាមួយ ដែលអ្នកសុំខ្ចីទទួលបាននូវវត្ថុមានតម្លៃភ្លាមៗ ហើយយល់ព្រមសងត្រលប់ដល់អ្នកឱ្យខ្ចីវិញនៅពេលក្រោយ។

- ឥណទាន: គឺជាមធ្យោបាយដោះដូរជាមួយនឹងការទទួលយក ដោយមានដែនកំណត់។

-ឥណទាន: គឺជាការសន្យាសងនៅពេលអនាគត ក្នុងគោលបំណងដើម្បីទិញជំពាក់ ឬសុំខ្ចីនាពេល បច្ចុប្បន្ន

**សង្ខេប៖** ឥណទាន គឺជាការផ្តល់ប្រាក់ ឬទ្រព្យសម្បត្តិដល់អ្នកខ្ចី ដោយមានលក្ខខណ្ឌជាក់លាក់សម្រាប់ការសងត្រលប់មកវិញ។

### ២.២.២ ប្រវត្តិឥណទាន

ប្រវត្តិឥណទាននៅកម្ពុជាមានភាពរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ១៩៨៩ ដោយមានការផ្តល់ឥណទានពីអង្គការសហប្រជាជាតិ ដើម្បីជួយស្ត្រីមេម៉ាយ កុមារកំព្រា និងចាស់ជរា ដែលខ្វះខាតកម្លាំងពលកម្មបន្ទាប់ពីសង្គ្រាម។ នៅឆ្នាំ១៩៩៩ អង្គការមូលដ្ឋានឥណទានបានផ្តល់ឥណទានដំបូងនៅខេត្តព្រៃវែង ដោយផ្តល់ជាពូជស្រូវ និងជី ដើម្បីជួយកសិករក្នុងការកសាងផលិតភាពកសិកម្ម។ បន្ទាប់មកអង្គការ និងធនាគារផ្សេងៗបានចូលរួមផ្តល់ឥណទានដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជា។ ក្នុងឆ្នាំ ២០២០ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការធានាឥណទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម។ បច្ចុប្បន្ននេះប្រព័ន្ធឥណទាននៅកម្ពុជាបានរីកចម្រើនយ៉ាងខ្លាំង ដោយមានការផ្តល់ឥណទានសម្រាប់គ្រប់វិស័យ ទៅដល់ប្រជាជនទាំងអស់។ការផ្តល់ឥណទានបានជួយសម្រួលដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងការកសាងសង្គមនៅកម្ពុជា។

### ២.២.៣ ប្រភេទឥណទាន

ប្រទេសកម្ពុជានៅប៉ុន្មានឆ្នាំចុងក្រោយនេះ មានសន្ទុះនៃការវិនិយោគលើវិស័យអចលនទ្រព្យមានការកើនឡើងយ៉ាងខ្លាំង ដោយមានបណ្តាខេត្តមួយចំនួនគេសង្កេតឃើញមានអគារខ្ពស់ៗ សំណង់ដែលមានទឹកប្រាក់វិនិយោគរាប់រយលានដុល្លារគ្របដណ្តប់ស្ទើរពេញខេត្ត-ក្រុងនៃផ្ទៃប្រទេស។ ទន្ទឹមគ្នានេះដែរកម្ចីនៃបណ្តាធនាគារ ក្រុមហ៊ុនភតិសន្យា ក៏ដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនក៏មានការកើនឡើងផងដែរ។ កម្ចីខ្លះខ្ចីក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន រីឯកម្ចីខ្លះទៀតខ្ចីក្នុងគោលបំណងវិនិយោគលើដីធ្លី និងផ្ទះសំបែង នៅតំបន់អភិវឌ្ឍន៍។ រូបភាពនៃការខ្ចីឥណទានទាំងនោះត្រូវបានបែងចែកជា ៤ ប្រភេទក្នុងស្តង់ដារនៃការផ្តល់កម្ចីរបស់ស្ថាប័នផ្តល់កម្ចី។ ដែលក្នុងនោះមានឥណទានក្រុមហ៊ុន ឥណទានសម្រាប់សហគ្រាសខ្នាតតូចនឹងមធ្យម ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន នឹងឥណទានរថយន្ត។

[8] Facebook Page. TOLA Banking. (2020, July 05). *តើឥណទានជាអ្វី?*. Retrieved June, 04 2025 from https://www.facebook.com/share/p/1DkDcay5MB/

- ឥណទានក្រុមហ៊ុន៖ ឥណទានក្រុមហ៊ុន ជាប្រភេទកម្ចីដែលភាគីខ្ចីភាគច្រើនគឺជាក្រុមហ៊ុនខ្នាតតូច មធ្យម និងធំ។ គោលបំណងនៃកម្ចីរបស់ពួកគេភាគច្រើនគឺចង់ពង្រីកនូវក្រុមហ៊ុនរបស់ខ្លួនឱ្យកាន់តែធំនឹងបង្កើនមូលធនសម្រាប់ តម្រូវការចាំបាច់ក្នុងដំណើរនៃប្រតិបត្តិការក្រុមហ៊ុន។ រីឯទំហំនៃទឹកប្រាក់កម្ចី គឺមានចំនួនច្រើនបើប្រៀបធៀបទៅនឹងកម្ចីឥណទានបីផ្សេងទៀត ហើយដំណើរការនៃការខ្ចីក៏មានភាពលំបាកផងដែរ។ ដោយត្រូវប្រាកដថាក្រុមហ៊ុនរបស់ខ្លួន គឺជាក្រុមហ៊ុនដែលមានទីតាំងច្បាស់លាស់ មុខរបរអាជីវកម្មជាក់លាក់ នឹងមានប្រាក់ចំណូលជាមធ្យមថេរ។

- ឥណទានសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម៖ ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ជាគឺជាប្រភេទ

ឥណទានផ្តល់ជូនអតិថិជនដែលមានតម្រូវការទិញ សម្ភារៈប្រើប្រាស់ផ្សេងៗក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ក្នុងគ្រួសារ។

- ឥណទានរថយន្ត៖ ឥណទានរថយន្តជាប្រភេទឥណទានខ្នាតតូច ដែលអ្នកខ្ចីឥណទានដើម្បីទិញរថយន្ត។ នៅក្នុងឆ្នាំ២០១៨ មកទល់នឹងបច្ចុប្បន្នឥណទានរថយន្តមានការកើនឡើងច្រើន ដោយក្រុមហ៊ុនលក់រថយន្តមួយចំនួន មានសេវាកម្មមិនត្រឹមតែលក់ឡានប៉ុណ្ណោះទេថែមទាំងផ្តល់សេវាកម្មបង់រំលស់ឡានជាប្រចាំខែថែមទៀតផង។ សេវាកម្មបង់រំលស់ឡានបានក្លាយជាទីចាប់អារម្មណ៍សម្រាប់អ្នក ដែលមានប្រាក់ចំណូលប្រចាំខែមធ្យមអាចមានលទ្ធភាពទិញរថយន្តផ្ទាល់ខ្លួនសម្រាប់ជួយសម្រួលដល់ការធ្វើដំណើរទៅទីជិត ឆ្ងាយ។

- បែបបទនៃការស្នើសុំប្រាក់កម្ចី៖ ចំពោះបែបបទនៃការស្នើសុំប្រាក់កម្ចី គឺវាមានភាពខុសគ្នាទៅតាមប្រភេទនៃកម្ចីដែលអ្នកខ្ចីត្រូវស្វែងយល់ខ្លះៗ អំពីប្រភេទនៃទម្រង់ការក្នុងការខ្ចី៖ គ្រប់កម្ចីទាំងអស់ត្រូវបានភ្ជាប់មកជាមួយពាក្យស្នើសុំឥណទានដែលមានចែងភាគីដែលជាអ្នកខ្ចី ថ្ងៃខែឆ្នាំកំណើត ភេទ អត្តសញ្ញាណបណ្ណ ស្រុកកំណើត នឹងធនាគារដែលពាក់ព័ន្ធ។

- ការស្នើសុំប្រាក់កម្ចីលើគម្រោងឥណទាន៖ ពាក្យស្នើសុំឥណទាន ដែលក្នុងពាក្យស្នើសុំនោះបានចែងថាឥណទានដែលអ្នកខ្ចី គឺជាប្រភេទឥណទានថ្មី ឬអ្នកចង់បន្ថែមឥណទុនចាស់ ឬក៏ចង់បន្តរយៈកាលនៃការខ្ចី។ ទន្ទឹមគ្នានោះដែរអ្នកត្រូវប្រាកដអំពីគោលបំណងនៃការប្រើប្រាស់កម្ចីដែលអ្នកខ្ចី ថាតើអ្នកចង់យកទៅប្រើការលើអ្វីខ្លះ? ចំនួនស្នើសុំក៏ជាបញ្ហាមួយដែរ សម្រាប់អ្នកខ្ចី ប្រសិនបើអ្នកចង់ខ្ចីបានប្រាក់កម្ចីច្រើននោះអ្នកក៏ត្រូវមានទ្រព្យដាក់បញ្ចាំច្រើនជាងប្រាក់កម្ចីនោះដល់ទៅពីរឬបីដង។ រយៈពេលខ្ចីនឹងអត្រាការប្រាក់ស្នើសុំវាពិតជារឿងមួយដែលអ្នកខ្ចីប្រាក់ទាំងអស់គួរ សិក្សាស្វែងយល់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនថាអាចមានលទ្ធភាពសងក្នុងរយៈកាលប៉ុន្មានឆ្នាំក្នុងអត្រាការប្រាក់ដ៏សមប្រកបមួយ[9]។

**២.២.៤ និយមន័យនីតិវិធី**

នីតិវិធី៖ គឺជាសំណុំនៃការណែនាំសម្រាប់បំពេញកិច្ចការ ឬសកម្មភាពជាក់លាក់មួយ។ ពេលខ្លះនីតិវិធីត្រូវបានចងក្រងជាឯកសារយ៉ាងលំអិត ដើម្បីធានាថាកិច្ចការត្រូវបានបញ្ចប់យ៉ាងជាប់លាប់ នឹងមានភាពជាក់លាក់។ លទ្ធផលចុងក្រោយនៃនីតិវិធី គឺការបញ្ចប់ការងារដោយជោគជ័យ តាមការណែនាំ[10]។

---

[9] រៀបរៀងដោយនិស្សិត អាត គីមមុី, ង៉ែត សេងហួយ, សឿង ស្រីមុី, អឹម ដានីត, ប៉ាក ស្រីនាត. (បោះពុម្ពឆ្នាំ២០២២). *ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ អេ អឹម ខេ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រ០៥-ទំព័រ០៦. ភ្នំពេញ។

[10] Pipefy. (2021, June 7). *What is a Procedure*. Retrieved June, 06 2025 from https://www.pipefy.com/blog/process-vs-procedure/

នីតិវិធី៖ គឺជាលំដាប់ជាប្រព័ន្ធនៃជំហានដែលធ្វើឡើងដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់មួយ។ ជារឿយៗមានការភ័ន្តច្រឡំជាមួយនឹងដំណើរការ សកម្មភាព នឹងការណែនាំការងារ នីតិវិធីគឺខុសគ្នាត្រង់ថាពួកគេផ្តោតលើស៊េរីនៃជំហានដែលបានអនុវត្តនៅក្នុងនាយកដ្ឋានជាក់លាក់មួយ[11]។

**២.២.៥ ប្រវត្តិនៃនីតិវិធី**

- នីតិវិធីដែលសរសេរបានល្អ ងាយស្រួលប្រើ គឺទាមទារឱ្យមានដំណើរការខ្ពស់។ ពួកគេបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការងារស្តង់ដារនៅកម្រិតស្ថាប័នណាមួយ បម្រើជាមូលដ្ឋានសម្រាប់កិច្ចខិតខំប្រឹងប្រែងចុះឈ្មោះដែលមានមូលដ្ឋានលើ ISO ហើយសំខាន់បំផុតគឺជួយមនុស្សឱ្យធ្វើការងាររបស់ពួកគេប្រកបដោយប្រសិទ្ធភាពជារៀងរាល់ថ្ងៃ។ ក្នុងករណីខ្លះយើងមានវា ប៉ុន្តែវាមានតួនាទីជាគ្រឹះសម្រាប់ធ្នើសៀវភៅដែលពេញដោយសៀវភៅកត់ត្រា។ ក្នុងករណីផ្សេងទៀត យើងជៀសវាងការប្រើប្រាស់ពួកវា ដោយសារបញ្ហាប្រឈមដែលយើងបានជួបប្រទះនាពេលកន្លងមក ហើយព្យាយាមអនុវត្តតាមនីតិវិធីសរសេរមិនល្អ។

នោះហើយជាកន្លែងដែលយើងត្រូវរកមើលប្រវត្តិសាស្ត្រនៃនីតិវិធីសម្រាប់ការយល់ដឹង។ បញ្ញាជាវត្ថុដែលកើតចេញពីភាពចាស់ បើមានចិត្តស្វែងរក។ នីតិវិធីបានចាប់ផ្តើមជាបញ្ជីនៅលើក្រដាស ការប្រើប្រាស់គោលបំណងរបស់ពួកគេ គ្រប់ករណីទាំងអស់ គឺមិនមែនដើម្បីណែនាំការអនុវត្តការងារដោយជោគជ័យនោះទេ ប៉ុន្តែផ្ទុយទៅវិញ កំណត់ថាតើវាគួរចំណាយពេលប៉ុន្មាន ដើម្បីអនុវត្តកិច្ចការនោះ។ ជាតុការងារគឺជាជំហាននៃនីតិវិធី ឬយ៉ាងហោចណាស់វាស្ថិតនៅក្នុងនីតិវិធីដែលបានសរសេរយ៉ាងល្អ។

នៅទីបំផុតយើងបានឈានដល់ចំណុចមួយនៅក្នុងភាពចាស់ទុំនៃនីតិវិធី ដែលយើងត្រូវបែងចែកភាគហ៊ុន ដូច្នេះដើម្បីនិយាយ - យើងបានបង្កើតនីតិវិធី នឹងការណែនាំការងារ។ ការណែនាំការងារបានក្លាយជាអ្វីដែលនីតិវិធីធ្លាប់មាន។ បញ្ហាគឺថាក្រុមហ៊ុនបានធ្លាក់ចុះហួសពីនេះ។ អំណាចនៃនីតិវិធីមិនត្រូវបានគេកោតសរសើរទេ ហើយជាលទ្ធផលធនធានមិនត្រូវបានបណ្តាក់ទុកក្នុងការថែទាំ ឬជំនាន់របស់ពួកគេទេ ទុកតែការកែលម្អរបស់ពួកគេ។

ក្នុងពេលដំណាលគ្នាជាមួយនឹងនីតិវិធីកំពុងធំឡើង (ប្រហែលជាង ៨៥ ឆ្នាំចុងក្រោយនេះ) មនុស្សកាន់តែមានភាពមមាញឹក (ឬយ៉ាងហោចណាស់អ្វីៗ ជាច្រើនទៀតកំពុងត្រូវបានបង្កើតឡើងដើម្បីកាន់កាប់ពេលវេលារបស់ពួកគេ)។ ជាលទ្ធផលពួកគេគេងតិច ពួកគេក៏បានញ៉ាំច្រើនផងដែរ នៅពេលអាហារចម្រុះកើនឡើង។ ក្នុងករណីខ្លះ ថ្នាំត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងផលប៉ះពាល់អវិជ្ជមាននៃអាកប្បកិរិយាថ្មីទាំងនេះ។ ក្នុងគ្រប់ករណីទាំងអស់ ការយល់ដឹង និងការចងចាំត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ តម្រូវការសម្រាប់នីតិវិធីដ៏អស្ចារ្យកំពុងកើនឡើង ប៉ុន្តែយើង(ហើយនៅតែ)ខកខានក្នុងការផ្តល់នូវការថែទាំបង្ការដែលនីតិវិធីរបស់យើងត្រូវការ។

ឥឡូវនេះមានការសន្និដ្ឋានបន្តិចនៅក្នុងរឿងខាងលើ ប៉ុន្តែភស្តុតាងជាច្រើនមានដើម្បីគាំទ្រដល់ខ្សែរឿងដែលសន្មត់។ ការជាប់ទាក់ទងគ្នារវាងការអនុវត្តការងារត្រឹមត្រូវ និងការប្រើប្រាស់នីតិវិធី ដែលយើងមានទំនោរនឹងបាត់បង់គឺនៅពេលដែលយើងគិតថានីតិវិធីគឺសម្រាប់តែអ្នកជួលថ្មីនិងអ្នកវិទ្យាសាស្ត្ររ៉ុក្កែត

[11] Gluu. (2018, April 19). *What is Procedure.* Retrieved June, 06 2025 from https://gluu.biz/process-management-glossary/procedure/

ប៉ុណ្ណោះ។ ភាពស្មុគស្មាញការងារបន្តកើនឡើង ខណៈពេលដែលយើងអាចប្រកែកថាសមត្ថភាពយល់ដឹងរបស់យើង រួមទាំងការចងចាំមិនកើនឡើងក្នុងអត្រាដូចគ្នា[12]។

- នីតិវិធីក្នុងការផ្តល់ឥណទានបានអភិវឌ្ឍតាមកាលវិភាគ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃប្រព័ន្ធហិរញ្ញវត្ថុ នឹងការគ្រប់គ្រងហានិភ័យ។ វាបានផ្លាស់ប្តូរពីប្រព័ន្ធសាមញ្ញនៅសម័យបុរាណទៅជាប្រព័ន្ធផ្តល់សេវាឥណទានទំនើបដែលផ្អែកលើបច្ចេកវិទ្យា នឹងបទដ្ឋានអន្តរជាតិ។ ការទំនាក់ទំនងរវាងធនាគារនិងអតិថិជនដែលធនាគារអាចផ្តល់ជូនសេវាកម្មឥណទានដែលមានប្រសិទ្ធភាពនឹងមានភាពត្រឹមត្រូវតាមគោលការណ៍អន្តរជាតិនៅលើផ្នែកការអនុវត្តច្បាប់ នឹងស្តង់ដារផ្សេងៗ។ នេះជាការប្រែប្រួលដ៏សំខាន់សម្រាប់ប្រព័ន្ធធនាគារនាពេលបច្ចុប្បន្ន ដែលបង្កើតនូវការកែលម្អ នឹងភាពអាចទុកចិត្តបានក្នុងការផ្តល់ឥណទាន

- **ដំណាក់កាលទី១៖** ការដាក់ពាក្យសុំខ្ចីប្រាក់: អ្នកដាក់ពាក្យសុំខ្ចីប្រាក់ គឺត្រូវមកទាក់ទងជាមួយធនាគារដើម្បីបំពេញបែបបទខ្ចីប្រាក់។ ចំណែកភ្នាក់ងារបម្រើអតិថិជន ត្រូវណែនាំ លក្ខខណ្ឌនៃការខ្ចី ការសងអត្រាការប្រាក់ ទំហំឥណទាន របៀបសង ការព្រមព្រៀងជានាគ្នា (ប្តី-ប្រពន្ធ អ្នកស្នងមរតក) លិខិតស្នាមដែលជាតម្រូវការរបស់ធនាគារ។
- **ដំណាក់កាលទី២៖** ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន: ក្រោយពីទទួលបានពាក្យស្នើសុំខ្ចី ហើយភ្នាក់ងារឥណទានចុះទៅដល់ផ្ទះអតីថិជន ដើម្បីប្រមូលព័ត៌មានហិរញ្ញវត្ថុ គោលបំណង នឹងតម្រូវការប្រើប្រាស់កម្ចី ព្រមទាំងព័ត៌មាន អំពីទ្រព្យធានាផងដែរ។ ក្រោយមកភ្នាក់ងារឥណទានត្រូវបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាពអាចទទួលឥណទាន លក្ខខណ្ឌឥណទាន បណ្តុះវិន័យឥណទាន។
- **ដំណាក់កាលទី៣៖**ការរៀបចំឯកសារឥណទាន:បន្ទាប់ពីមានការព្រមព្រៀងគ្នាហើយភ្នាក់ងារឥណទានត្រូវរៀបចំឯកសារខ្ចីប្រាក់ជូនអតិថិជនដែលក្នុងនោះរួមមានគម្រោងជំនួយក្រុមពាក្យសុំខ្ចី នឹងកិច្ចសន្យាធានាអះអាង។ បន្ទាប់មកភ្នាក់ងារឥណទានសរសេរយោបល់ នឹងសំណើសុំអនុម័ត តែលុះត្រាណាដែលអតិថិជនយល់ព្រមដាក់ទ្រព្យធានាបំណុល។
- **ដំណាក់កាលទី៤៖** ការអនុម័តឥណទាន: ភ្នាក់ងារឥណទានប្រគល់ឯកសារឥណទាន ដែលត្រូវអនុម័តទៅជូនជំនួយការរដ្ឋបាល ដើម្បីដាក់ជូនថ្នាក់លើដែលមានសមត្ថកិច្ចអនុម័ត។
- **ដំណាក់កាលទី៥៖** ការបញ្ចូលទិន្នន័យ: បន្ទាប់ពីឥណទានត្រូវបានអនុម័ត ហើយត្រូវបានបញ្ជូនឯកសារនោះទៅគណនេយ្យករ ដើម្បីពិនិត្យឯកសារឡើងវិញឱ្យបានច្បាស់លាស់ នឹងបញ្ចូលទៅក្នុងប្រព័ន្ធ Globus ឬ Click Loan។
- **ដំណាក់កាលទី៦៖** ការបញ្ចេញឥណទាន: ភ្នាក់ងារបម្រើអតិថិជន ត្រូវជូនអតិថិជនទៅបេឡាធិការដើម្បីបើកដោយតម្រូវឱ្យអតិថិជនត្រូវផ្តិតមេដៃលើ កិច្ចសន្យាខ្ចីប្រាក់ ប័ណ្ណចំណាយប្រាក់ឱ្យខ្ចី ឬប័ណ្ណដកប្រាក់ ហើយប្រគល់ប្រាក់ឱ្យអតិថិជន។ ប៉ុន្តែមុននឹងទទួលបានប្រាក់ បេឡាធិការរំលឹកពីគោលការណ៍ នឹងលក្ខខណ្ឌនៃកម្ចីម្តងទៀត[13]។

[12] Linknedin. (Jan 24, 2016). *A Brief History of Procedure.* Retrieved June, 06 2025 from https://www.linkedin.com/pulse/brief-history-procedures-kevin-mcmanus

[13] រៀបរៀងដោយនិស្សិត. បូជាលីន និង នីន វិបុល. (បោះពុម្ពឆ្នាំ ២០១៩). *"ដំណើរការនៃការផ្តល់ឥណទានឈ្មោះអ្នកចងក្រង"* សារណាថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភិមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ទំព័រ១២. ភ្នំពេញ។

### ២.២.៦ សារៈសំខាន់នៃនីតិវិធី

នីតិវិធីក្នុងការផ្តល់ឥណទាន មានសារសំខាន់យ៉ាងខ្លាំងសម្រាប់ទាំងធនាគារ និងអតិថិជន។ វាប្រើសម្រាប់ធានាបាននូវប្រសិទ្ធភាព នឹងសុវត្ថិភាព ក្នុងការប្រើប្រាស់ប្រាក់កម្ចី ហើយក៏ជួយបង្កើតស្ថេរភាពក្នុងវិស័យហិរញ្ញវត្ថុ។

១. ការពារហានិភ័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ជួយធនាគារក្នុងការវាយតម្លៃសមត្ថភាពសងប្រាក់របស់អតិថិជន ដើម្បីបង្ការការខាតបង់។
- កាត់បន្ថយហានិភ័យឥណទាន (Credit Risk) នឹងការលូតលាស់នៃបំណុលរបស់អតិថិជន។
- ធានាបាននូវស្ថេរភាពរបស់ប្រព័ន្ធធនាគារ នឹងភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច។

២. ទប់ស្កាត់ការប្រើប្រាស់ឥណទានខុសបំណង

- ជួយត្រួតពិនិត្យប្រភព នឹងគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចី ដើម្បីទប់ស្កាត់ការប្រើប្រាស់ក្នុងការលួចលាងប្រាក់ (Money Laundering) នឹងហិរញ្ញប្បទាន ការធ្វើអំពើខុសច្បាប់។
- ការពារ ការយកប្រាក់កម្ចីទៅប្រើប្រាស់លើវិស័យដែលមានហានិភ័យខ្ពស់។

៣. ការបង្កើនទំនុកចិត្តរវាងធនាគារ និងអតិថិជន

- ធានាបាននូវកិច្ចព្រមព្រៀងដ៏សមរម្យ ដើម្បីធ្វើឱ្យអតិថិជនមានទំនុកចិត្តលើសេវាកម្ម។
- ជួយអតិថិជនអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ នឹងការចំណាយ។
- បង្កើនការចូលរួមរបស់អតិថិជនក្នុងប្រព័ន្ធហិរញ្ញវត្ថុ។

៤. បង្កើតស្តង់ដារសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុ

- ធានាបាននូវភាពសាមញ្ញ នឹងស្តង់ដារប្រតិបត្តិការទូទាំងប្រព័ន្ធធនាគារ។
- បង្កើតលក្ខណៈស្របច្បាប់ នឹងអនុលោមតាមបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល (Compliance)។
- ជួយធានាបាននូវការប្រកួតប្រជែងស្មើភាពក្នុងទីផ្សារ។

៥. ជំរុញការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច

- ផ្តល់ឥណទានដល់អាជីវករ នឹងសហគ្រាស ដើម្បីជួយពង្រីកអាជីវកម្ម។
- ជួយបង្កើនការវិនិយោគ នឹងការចំណាយក្នុងសេដ្ឋកិច្ច។
- បង្កើតឱកាសការងារបន្ថែម[14]។

## ២.៣ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព

### ២.៣.១ និយមន័យយុទ្ធសាស្ត្រការគ្រប់គ្រង

យុទ្ធសាស្ត្រការគ្រប់គ្រង (Management Strategy) គឺជាសិល្បៈនិងជាវិទ្យាសាស្ត្រនៃការរៀបចំការអនុវត្តន៍និងវាយតម្លៃការសម្រេចចិត្តអន្តរមុខងារដែលអាចឲ្យអង្គភាពសម្រេចបានបំណងរបស់គេ[15]។

[14] ងួន ហេង. (បោះពុម្ពឆ្នាំ២០២៣). *ដំណើរការនៃការផ្តល់ឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី.* សារណាថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យគិមិទ្ធនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ទំព័រ ៤១

[15] KHsearch. ការគ្រប់គ្រង. (2020, May 29). *តើការគ្រប់គ្រងយុទ្ធសាស្ត្រគឺជាអ្វី?*. Retrieved June, 06 2025 from https://www.khsearch.com/qna/31420

ម្យ៉ាងវិញទៀតយុទ្ធសាស្ត្រការគ្រប់គ្រង គឺជាកត្តាសំខាន់ក្នុងការដឹកនាំអង្គភាពឱ្យទទួលបានជោគជ័យ។ មិនតែប៉ុណ្ណោះវាអាចជួយក្រុមហ៊ុន ឬអង្គភាពឱ្យកំណត់ទិសដៅយ៉ាងច្បាស់លាស់ នឹងអភិវឌ្ឍការប្រកួតប្រជែងយ៉ាងមានប្រសិទ្ធភាព។

**២.៣.២ ទ្រឹស្តីយុទ្ធសាស្ត្រការគ្រប់គ្រង**

**និយមន័យទូទៅនៃទ្រឹស្តីនៃការគ្រប់គ្រង:** គឺជាអង្គការចាត់តាំងមានសមូហភាពមួយដែលមនុស្សនឹងធនធានទាំងឡាយត្រូវបានសម្របសម្រួល តាមរយៈការបែងចែកពលកម្ម ការអនុវត្តវិទ្យាសាស្ត្របច្ចេកទេសដើម្បីសម្រេចផែនការឬគោលដៅណាមួយ។

ក. ទ្រឹស្តីគោលនយោបាយទូទៅ (General Strategy Theory) Michael Porter បានអភិវឌ្ឍទ្រឹស្តីនេះដោយផ្តោតលើភាពឈ្នះការប្រកួតប្រជែង (Competitive Advantage) ដោយប្រើចំណុចខ្លាំងរបស់អង្គភាព។ អាជីវកម្មអាចប្រើយុទ្ធសាស្ត្រថ្លៃថោក (Cost Leadership) ភាពខុសគ្នា (Differentiation) ឬការផ្តោតលើទីផ្សារជាក់លាក់ (Focus Strategy) ដើម្បីទទួលបានអត្ថប្រយោជន៍។

ខ. ទ្រឹស្តីធនធាន និងសមត្ថភាព (Resource-Based View - RBV) បង្កើតដោយ Barney (១៩៩១) ទ្រឹស្តីនេះលើកឡើងថា ធនធានក្នុងអង្គភាព (Resources) នឹងសមត្ថភាព (Capabilities) ជាសោគីលេខសម្រាប់ភាពជោគជ័យ។ ធនធានត្រូវមានលក្ខណៈដូចជា មានតម្លៃ (Valuable) កម្របាន (Rare) ពិបាកចម្លង (Inimitable) នឹងមិនងាយជំនួស (Non-substitutable)។

គ. ទ្រឹស្តីចក្ខុវិស័យ និងបេសកកម្ម (Vision and Mission Theory) អង្គភាពត្រូវមានចក្ខុវិស័យ (Vision) ដើម្បីបញ្ជាក់ពីអនាគតដែលពួកគេចង់សម្រេចបាន។ បេសកកម្ម (Mission) បង្ហាញពីអត្ថបទអាជីវកម្ម នឹងគោលដៅដែលត្រូវអនុវត្ត។

ឃ. ទ្រឹស្តីស្ថេរភាពនៃយុទ្ធសាស្ត្រ (Strategic Stability vs. Adaptability) បណ្តាស្ថាប័នអាចជ្រើសរើសយុទ្ធសាស្ត្រស្ថេរភាព (Stable Strategy) ដែលផ្តោតលើការរក្សាភាពរឹងមាំ ឬយុទ្ធសាស្ត្រកែប្រែ (Adaptive Strategy) ដែលផ្តោតលើការប្រើប្រាស់ឱកាសថ្មី។

ង.ទ្រឹស្តីអាជីវកម្មអេឡិចត្រូនិក (E-Business Strategy Theory) ភាពរីកចម្រើននៃបច្ចេកវិទ្យាឌីជីថលបានធ្វើឱ្យអាជីវកម្មផ្លាស់ប្តូរទៅជាស្ថាប័នអេឡិចត្រូនិក(E-business)ដើម្បីប្រកួតប្រជែងបានកាន់តែប្រសើរឡើ[16]។

**២.៣.៣ និយមន័យហានិភ័យឥណទាន**

ហានិភ័យឥណទានគឺជាហានិភ័យដែលបណ្តាលមកពីអតិថិជនខកខាន មិនបានសងការប្រាក់នឹងប្រាក់ដើមត្រឡប់មកធនាគារវិញ ឬអតិថិជនមិនគោរពទៅតាមកិច្ចសន្យា[17]។

**២.៣.៤ ប្រវត្តិហានិភ័យឥណទាន**

### ក. សារសំខាន់នៃប្រវត្តិហានិភ័យឥណទាន

- វាស់ស្ទង់សមត្ថភាពសងបំណុល ប្រវត្តិឥណទានល្អអាចជួយអ្នកទទួលបានឥណទានថ្មី ដោយមានលក្ខខណ្ឌប្រសើរ។

[16] រៀបរៀងដោយនិស្សិត ងួន ហេង. (បោះពុម្ពឆ្នាំ ២០២៣). *ដំណើរការនៃការផ្តល់ឥណទានខ្នាតតូចនិងមធ្យមរបស់គ្រឹះស្ថានហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី*. សារណាថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភិមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ទំព័រ៤១. ភ្នំពេញ។

[17] វិទ្យាស្ថាន វ៉ាន់ដា. (២០១៧). *រូបិយវត្ថុ និងធនាគារ ភាគ២*. បោះពុម្ពលើកទី៤. ទំព័រ៩. ភ្នំពេញ។

- ប៉ាន់ប្រមាណហានិភ័យសម្រាប់អ្នកផ្ដល់ឥណទានធនាគារ នឹងស្ថាប័នឥណទានប្រើប្រវត្តិនេះដើម្បីវាយតម្លៃហានិភ័យសងបំណុលរបស់អតិថិជន។

- ប៉ះពាល់ទៅលើអត្រាការប្រាក់ ប្រសិនបើអ្នកមានប្រវត្តិឥណទានល្អ អ្នកអាចទទួលបានអត្រាការប្រាក់ទាប។

**ខ. ធាតុសំខាន់ក្នុងប្រវត្តិហានិភ័យឥណទានមាន**

- ប្រវត្តិសងប្រាក់
- ចំនួនបំណុលកំពុងមាន
- ប្រវត្តិជាប់កាតព្វកិច្ច ឬបោះបង់បំណុល
- ព័ត៌មានអំពីបញ្ជីខ្មៅ ឬលិខិតប្ដឹងបឋម
- ហានិភ័យកម្ចី ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ ហានិភ័យអត្រាការប្រាក់ ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យបច្ចេកវិទ្យា ហានិភ័យអត្រាប្ដូរប្រាក់ ហានិភ័យច្បាប់ និងហានិភ័យយុទ្ធសាស្ត្រ។

### ២.៣.៥ ទ្រឹស្តីហានិភ័យឥណទាន

❖ **និយមន័យ**

❖ ទ្រឹស្ដីហានិភ័យឥណទាន (Credit Risk Theory) ជាទ្រឹស្ដីដែលពិភាក្សា នឹងវិភាគពីហានិភ័យដែលធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗអាចជួបប្រទះ នៅពេលផ្ដល់ឥណទានឱ្យអតិថិជន។ ហានិភ័យនេះស្ថិតនៅក្នុងការមិនអាចសងប្រាក់វិញ ឬការសងយឺតពេល។

❖ **ទ្រឹស្ដីសំខាន់ៗអំពីហានិភ័យឥណទាន**

- ទ្រឹស្ដី **Asymmetric Information:** អ្នកខ្ចីប្រាក់ (borrower) មានព័ត៌មានច្រើនជាងអ្នកបើកប្រាក់កម្ចី (lender) អំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ បណ្ដាលឱ្យមាន Adverse Selection (ការជ្រើសរើសខុស) និង Moral Hazard (ការប្រព្រឹត្តខុសសីលធម៌)។

- ទ្រឹស្ដី **Credit Rationing (Stiglitz & Weiss 1981):** ធនាគារមិនផ្ដល់ឥណទានដល់អតិថិជនទាំងអស់ទោះបីមានអត្រាការប្រាក់ទាប។ ជ្រើសរើសអតិថិជនដោយផ្អែកលើប្រវត្តិឥណទាន នឹងសិទ្ធិកាន់កាប់បណ្ដោះអាសន្ន។

- ទ្រឹស្ដី **Structural Models (Merton Model 1974):** វិភាគហានិភ័យឥណទានដោយប្រើ option pricing theory ដើម្បីកំណត់សមភាពរវាងទ្រព្យសម្បត្តិ និងបំណុល។

- ទ្រឹស្ដី **Reduced-form Models (Jarrow & Turnbull 1995):** វិភាគហានិភ័យឥណទានដោយប្រើ default probability ដើម្បីប៉ាន់ស្មានការបោកបញ្ឆោត ឬការមិនអាចសងប្រាក់វិញ។

- ទ្រឹស្ដី Machine Learning & Credit Risk Assessment: ប្រើអាល្គរីធម៍ស្វ័យបណ្ដោះអាសន្ន (AI & ML) ដើម្បីវាយតម្លៃលទ្ធភាពខ្ចីប្រាក់ នឹងការអនុលោមឥណទាន។

❖ **វិធីសាស្ត្រកាត់បន្ថយហានិភ័យឥណទាន**

- Diversification: បែងចែកឥណទានទៅលើអតិថិជនច្រើនប្រភេទ។
- Collateral: ប្រើបញ្ចាំបំភ្លឺការសងប្រាក់វិញ។
- Credit Scoring Models: ប្រើអត្ថបទចំណាត់ថ្នាក់ឥណទាន (FICO, Altman’s z-score) ។
- Loan Covenants: ដាក់លក្ខខណ្ឌក្នុងកិច្ចសន្យាឥណទាន។

ហានិភ័យឥណទានជាបញ្ហាសំខាន់សម្រាប់ស្ថាប័នហិរញ្ញវត្ថុ។ ការយល់ដឹងពីទ្រឹស្តីនៃហានិភ័យឥណទានអាចជួយក្នុងការគ្រប់គ្រងនឹងបង្ការហានិភ័យបានប្រសើរជាងមុន[18]។

[18] រៀបរៀងដោយនិស្សិត ថន ស្រីពេជ្រ. (បោះពុម្ពឆ្នាំ២០២២). *ដំណើការនៃការស្វែងរកអតិថិជនក្នុងការផ្តល់ប្រាក់កម្ចី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រង. ទំព័រ១០. ភ្នំពេញ។

# ជំពូកទី៣

# ដំណើរការនៃការផ្ដល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក.អ

## ៣.១ ស្ថានភាពទូទៅរបស់ធនាគារ សហពាណិជ្ជ ក.អ




### ៣.១.១ ប្រវត្តិរបស់ធនាគារ សហពាណិជ្ជ ក.អ

Union Commercial Bank PLC ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ១៩៩៤ ហើយបច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយធនាគារ E.SUN ១០០% ។ UCB គឺជាធនាគារពាណិជ្ជដែលមានអាជ្ញាប័ណ្ណពេញលេញដែលមានសាខាចំនួន ១២ នៅរាជធានីភ្នំពេញ និងសាខាចំនួន ២ នៅខេត្តផ្សេងទៀត ដែលមានបុគ្គលិកជាង ៥០០ នាក់។ UCB ទទួចលើគុណតម្លៃ និងចក្ខុវិស័យស្នូលរបស់ E.SUN ហើយប្រកាន់ខ្ជាប់នូវទស្សនវិជ្ជាអាជីវកម្មនៃ "ជំនាញ សេវាកម្ម និងធុរកិច្ច" ដើម្បីផ្តល់នូវបទពិសោធន៍សេវាកម្មដ៏វិសេសវិសាល នឹងរួមចំណែកដល់សង្គមកម្ពុជា។ UCB នឹងបន្តលើកកម្ពស់ផលិតផលហិរញ្ញវត្ថុ សេវាកម្ម ការច្នៃប្រឌិត នឹងពន្លឿនកិច្ចសហប្រតិបត្តិការក្នុងចំណោមឥស្សរជនពហុវប្បធម៌ ដើម្បីក្លាយជាធនាគារបរទេសកំពូលនៅកម្ពុជា។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ធនាគារ សហពាណិជ្ជ ក.អ

ដើម្បីក្លាយជាធនាគារឈានមុខគេនៅកម្ពុជា ដោយផ្តល់នូវបទពិសោធន៍សេវាកម្មដ៏វិសេសវិសាល នឹងរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ បេសកកម្មរបស់ពួកគេគឺដើម្បីបង្កើនផលិតផលហិរញ្ញវត្ថុ សេវា

កម្ម នឹងការច្នៃប្រឌិត ខណៈពេលដែលការពន្លឿនការអប់រំ នឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមឥស្សរជនពហុវប្បធម៌។ UCB មានបំណងក្លាយជាធនាគារបរទេសដ៏ប្លែកមួយនៅកម្ពុជា។

**ក.ចក្ខុវិស័យ៖**

-ដើម្បីក្លាយជាធនាគារនៃជម្រើសដំបូងតាមរយៈការបង្កើនតម្លៃអតិបរមាសម្រាប់អតិថិជន ម្ចាស់ភាគហ៊ុន និងបុគ្គលិក។

- ដើម្បីក្លាយជាធនាគារលំដាប់ពិភពលោកដែលឧទ្ទិសដល់ឧត្តមភាព នឹងលើសពីការរំពឹងទុកខ្ពស់បំផុតរបស់អតិថិជន និងអ្នកពាក់ព័ន្ធ។

**ខ.បេសកកម្ម៖**

-ដើម្បីក្លាយជាអ្នកដឹកនាំដែលគ្មានជម្លោះក្នុងសេវាកម្មហិរញ្ញវត្ថុសម្រាប់អតិថិជន ការច្នៃប្រឌិត និងភាពរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងអាជីវកម្មគោលដៅ។

-ដើម្បីផ្តល់នូវបទពិសោធន៍ធនាគារដ៏ល្អតាមរយៈអ្នកជំនាញដែលមានសមត្ថភាពនឹងយកចិត្តទុកដាក់ដែលផ្តល់អាទិភាពដល់តម្រូវការរបស់អតិថិជន។

-ដើម្បីរួមចំណែកជាវិជ្ជមានដល់សហគមន៍ដែល ធនាគារUCB ប្រតិបត្តិការ។

**គ. គោលដៅ៖**

-ដើម្បីបង្កើនផលិតផលហិរញ្ញវត្ថុ សេវាកម្ម និងការច្នៃប្រឌិត។

-ដើម្បីពន្លឿនការអប់រំ នឹងកិច្ចសហប្រតិបត្តិការរវាងឥស្សរជនពហុវប្បធម៌។

-ដើម្បីក្លាយជាធនាគារបរទេសដ៏ប្លែកមួយនៅកម្ពុជា។

-ដើម្បីរួមបញ្ចូលនិរន្តភាពទៅក្នុង DNA របស់ធនាគារ នឹងកំណត់ស្តង់ដារឧស្សាហកម្ម។

-ដើម្បីសម្រេចបាននូវការរួមបញ្ចូលពេញលេញនៃនិរន្តរភាពទៅក្នុងប្រតិបត្តិការ នឹងការវិនិយោគរបស់ធនាគារ។

-ដើម្បីជំរុញឱ្យវិស័យធនាគារកាន់តែទូលំទូលាយដើម្បីទទួលយក នឹងពន្លឿនការផ្លាស់ប្តូរទៅកាន់អនាគតពណ៌បៃតង នឹងចូលរួមចំណែកកាន់តែច្រើនឡើង។

### ៣.១.៣ រចនាសម្ព័ន្ធរបស់ធនាគារ សហពាណិជ្ជ ក អ




## ៣. ២ នីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក. អ

### ៣.២.១ ប្រភេទនៃឥណទាន

ធនាគារសហពាណិជ្ជ ក.អ មានឥណទានជាច្រើនប្រភេទដូចជា ឥណទានគេហដ្ឋាន ឥណទានវិនិយោគលើគេហដ្ឋាន ឥណទានអាជីវកម្មខ្នាតតូច ឥណទានរិបារូបន៍ ឥណទានពាណិជ្ជកម្ម។

#### ក. ឥណទានគេហដ្ឋាន

- ឥណទានគេហដ្ឋាន **(Home Loan)** គឺជាប្រភេទកម្ចីបង់រំលស់សម្រាប់ផ្តល់ជូនបុគ្គលិកក្រុមហ៊ុន មន្ត្រីរាជការ អាជីវករ ពាណិជ្ជករ ផលិតករ អ្នកផ្តល់សេវាកម្ម និងអ្នកជំនួញស្របច្បាប់គ្រប់ប្រភេទជារូបវន្តបុគ្គល ដើម្បីយកទៅទិញគេហដ្ឋានថ្មី សាងសង់ផ្ទះលើដីកម្មសិទ្ធិដែលមានស្រាប់ សម្រាប់រស់នៅផ្ទាល់ខ្លួន ឬជាលក្ខណៈក្រុមគ្រួសារ ហើយសងត្រឡប់មកធនាគារវិញដោយផ្អែកលើចំណូលទៀងទាត់ប្រចាំខែរបស់ខ្លួន។

- ឥណទានគេហដ្ឋាន **(Home Loan)** គឺជាឥណទានដែលធនាគារផ្តល់ជូនដើម្បីជួយអ្នកទិញ ឬសាងសង់គេហដ្ឋានផ្ទាល់ខ្លួន។

- ឥណទានគេហដ្ឋាន **(Home Loan)** គឺជាឥណទានដែលធនាគារឬស្ថាប័នហិរញ្ញវត្ថុផ្តល់ជូនដល់បុគ្គល ឬគ្រួសារដែលចង់ទិញ ឬសាងសង់ផ្ទះ។ ឥណទាននេះផ្តល់ជូនប្រាក់កម្ចីសម្រាប់ការទិញដីឬផ្ទះ ហើយអ្នកខ្ចីត្រូវតែបង់ការប្រាក់ទៅតាមពេលវេលា ដែលបានកំណត់ជាមួយធនាគារដែលផ្តល់ឥណទាន។

☞ **ប្រភេទឥណទានគេហដ្ឋានមាន:**

១. ឥណទានទិញផ្ទះប្រើប្រាស់សម្រាប់ការទិញផ្ទះដែលអ្នកខ្ចីអាចប្រើប្រាក់កម្ចីដើម្បីទិញផ្ទះពីអ្នកលក់។

២. ឥណទានសាងសង់ផ្ទះ សម្រាប់ការសាងសង់ផ្ទះថ្មី ឬការជួសជុលផ្ទះដែលមានស្ថានភាពជាមុន។

៣. ឥណទានប្រាក់ស្នាក់នៅ ប្រើប្រាស់ប្រាក់ពីការប្រាក់នៅលើជំហរនៃផ្ទះដែលអ្នកមាន។

៤. ឥណទានសំរាប់ជួសជុលផ្ទះ ប្រើប្រាស់សម្រាប់ការជួសជុល ឬបន្ថែមលើផ្ទះដែលមានស្រាប់។

+ ទំហំឥណទានអប្បបរមាគឺ ២០,០០០ (ម្ភៃពាន់) ដុល្លារអាមេរិកឡើងទៅសម្រាប់អតិថិជនចាស់ដោយត្រូវអនុវត្តដូចខាងក្រោម ៖

- ករណីទ្រព្យដាក់ធានាជាគេហដ្ឋានដែលត្រូវទិញឬសាងសង់៖ ទំហំឥណទានអតិបរមាគឺ ៧០% នៃតម្លៃសរុបរបស់គេហដ្ឋានដែលត្រូវទិញ ឬសរុបថវិកាចំណាយសាងសង់ករណីទ្រព្យដាក់ធានាជា ដី ផ្ទះ អគារដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹងចុះការីបន្ទុក) ជាកម្មសិទ្ធិផ្ទាល់របស់អ្នកខ្ចីដាក់ធានាជំនួស ឬបន្ថែមពីលើទ្រព្យដែលបានទិញ ឬសាងសងដោយប្រាក់កម្ចី ត្រូវអនុវត្តតាមលក្ខខណ្ឌ ទំហំឥណទានអតិបរមាអាចស្មើ ១០០% នៃតម្លៃសរុបគេហដ្ឋានដែលត្រូវទិញ ឬសរុបថវិការចំណាយសាងសង់ នឹងអនុបាតប្រាក់កម្ចីមិនលើសពី ៧៥% នៃតម្លៃទីផ្សាររបស់ទ្រព្យដាក់ធានា ។

**ខ.ឥណទានវិនិយោគលើគេហដ្ឋាន (Home Investment Loan)**

ឥណទានវិនិយោគលើគេហដ្ឋាន **(Home Investment Loan)** គឺជាឥណទានដែលធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្តល់ជូនសម្រាប់ការវិនិយោគលើអចលនទ្រព្យដែលអ្នកមានផ្ទះ ឬមានផែនការចង់ទិញផ្ទះ ឬអចលនទ្រព្យផ្សេងៗ ដើម្បីទទួលបានប្រាក់ចំណេញពីការជួល ឬការលក់វិញក្នុងពេលក្រោយ។

☞ **ប្រភេទឥណទានវិនិយោគលើគេហដ្ឋានមាន:**

១.ឥណទានវិនិយោគសម្រាប់ទិញផ្ទះ: សម្រាប់ជួលប្រើសម្រាប់ការទិញផ្ទះដែលមានគោលបំណងដើម្បីជួលនឹងទទួលប្រាក់ចំណូលប្រចាំខែពីការជួល។

២.ឥណទានវិនិយោគសម្រាប់ការអភិវឌ្ឍអចលនទ្រព្យ ប្រើសម្រាប់ការអភិវឌ្ឍអចលនទ្រព្យដូចជាការសាងសង់ផ្ទះថ្មី ឬធ្វើការជួសជុលអចលនទ្រព្យដើម្បីលក់ ឬជួល។

៣.ឥណទានវិនិយោគសម្រាប់ការផ្លាស់ប្តូរផ្ទះ ប្រើសម្រាប់ការទិញផ្ទះដែលត្រូវការជួសជុល ឬកែសម្រួលនឹងលក់វាក្តី ជាអចលនទ្រព្យថ្មីក្នុងរយៈពេលខ្លី ដើម្បីទទួលប្រាក់ចំណេញ។

**គ. ឥណទានកែលម្អគេហដ្ឋាន**

ឥណទានកែលម្អលំនៅឋាន គឺជាប្រភេទកម្ចីបង់រំលស់សម្រាប់ផ្តល់ជូនបុគ្គលិកក្រុមហ៊ុន មន្ត្រីរាជការ អាជីវករ ពាណិជ្ជករ ផលិតករ អ្នកផ្តល់សេវាកម្ម និងអ្នកជំនួញស្របច្បាប់គ្រប់ប្រភេទជារូបវន្តបុគ្គល ដើម្បីយកទៅជួសជុល សង់ថែម ឬកែលម្អលំនៅឋាន នឹងបរិវេណជុំវិញ សំដៅធ្វើឱ្យលក្ខខណ្ឌរស់នៅផ្ទាល់ខ្លួនឬក្រុមគ្រួសារមានភាពល្អប្រសើរជាងមុន ហើយសងត្រឡប់មកធនាគារវិញដោយផ្អែកលើប្រាក់ចំណូលទៀងទាត់ប្រចាំខែរបស់ខ្លួន។ ឥណទានកែលម្អលំនៅឋាន ត្រូវបានផ្តល់ជូនអតិថិជនជាប្រាក់ដុល្លារអាមេរិក ឬប្រាក់រៀល ។

☞**ដើម្បីទទួលឥណទានកែលម្អលំនៅឋានបាន អ្នកខ្ចីត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖**

មានទីលំនៅអចិន្ត្រៃយ៍ដោយមានឯកសារបញ្ជាក់អត្តសញ្ញាណពីអាជ្ញាធរក្នុងតំបន់ដូចជា:

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ លិខិតឆ្លងដែន សៀវភៅស្នាក់នៅ ឬលិខិតផ្សេងទៀតដែលអាចជំនួសបាន។

-ចំណូលពីមុខរបរអាជីវកម្ម: គម្រោងជំនួញ ឬរបាយការណ៍ប្រាក់ចំណូល ។

-ចំណូលពីប្រាក់បៀវត្សៈយល់ព្រមផ្តល់ឯកសារអំពីប្រាក់បៀវត្សមានលិខិតបញ្ជាក់ពីអ្នកគ្រប់គ្រងផ្ទាល់ ឬច្បាប់ចតចម្លងកិច្ចសន្យាការងារ ។

- ចំណូលបន្ទាប់បន្សំផ្សេងទៀត ។

- ថតចម្លងសក្ខីប័ត្របៀវត្សរយៈពេល ០៣ខែ ចុងក្រោយ ឬលិខិតបញ្ជាក់ពីនិយោជក អំពីឋានៈ តួនាទី រយៈពេលកំពុងបម្រើការងារ នឹងប្រវត្តិប្រាក់បៀវត្ស ។

- ថតចម្លងវិក្កយបត្រថ្លៃទឹក ភ្លើង និងឯកសារចំណាយក្នុងគ្រួសាររយៈពេល ០៣ខែ ចុងក្រោយ ។

- សៀវភៅគណនី ឬថតចម្លងរបាយការណ៍ធនាគាររយៈពេល ០៣ខែ ចុងក្រោយ " បើមាន"។

- កិច្ចសន្យាជួលទ្រព្យសម្បត្តិ " បើមាន " ។

- មានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់រយៈពេលមួយឆ្នាំចុងក្រោយ " បើមានមុខរបរបន្ថែម " ។

- ក្នុងករណីចាំបាច់តម្រូវឱ្យមានអ្នកធានា ហើយអ្នកធានាត្រូវមានមុខរបរខុសគ្នាពីអ្នកខ្ចី ។

**ឃ. ឥណទានអាជីវកម្មខ្នាតតូច**

ឥណទានអាជីវកម្មខ្នាតតូច គឺជាឥណទានមួយប្រភេទសម្រាប់ផ្តល់ជូនអតិថិជនជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រកបអាជីវកម្មខ្នាតតូច ឬមុខរបរតូចតាចលក្ខណៈគ្រួសារដើម្បីឱ្យអាជីវករមានការពង្រីកមធ្យោបាយដើម្បី បង្កើនប្រាក់ចំណូលក្នុងសកម្មភាពប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។

☞ **ដើម្បីទទួលឥណទានអាជីវកម្មខ្នាតតូចបាន អ្នកខ្ចីត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖**

- មានទីលំនៅអចិន្ត្រៃយ៍ ដោយមានឯកសារបញ្ជាក់អត្តសញ្ញាណពីអាជ្ញាធរក្នុងតំបន់ដូចជាៈ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ លិខិតឆ្លងដែន សៀវភៅស្នាក់នៅ ឬលិខិតផ្សេងៗទៀតដែលអាចជំនួសបាន

- ឯកសារអាជីវកម្មស្របច្បាប់ (ប្រសិនបើមាន)

- គម្រោងជំនួញ ឬមុខរបរច្បាស់លាស់ដែលបង្ហាញថាមុខរបរមានសក្តានុពលមានប្រាក់ចំណេញ នឹងមាននិរន្តរភាព។

- លំហូរសាច់ប្រាក់ទៀងទាត់ អាចសងឥណទាន។

- ប្រើប្រាស់គណនីនៅធនាគារ។

- មានទុនផ្ទាល់ខ្លួនក្នុងមុខរបរយ៉ាងតិច ២០% នៃទុនវិនិយោគសរុប ។

-ទ្រព្យសម្បត្តិដាក់ធានាមានតម្លៃធានាបំណុលបានទាំងប្រាក់ដើមនិងការប្រាក់។ ករណីយល់ថាមិនអាចសងបំណុលបានទាន់ពេលវេលាអតិថិជនត្រូវតែរកអ្នកធានាដែលមានសមត្ថភាពអាចសងបំណុលជំនួសបាន។

- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីបទល្មើសផ្សេងៗ ។

**ង. ឥណទានវិបារូបន៍**

ឥណទានវិបារូបន៍ គឺជាប្រភេទកម្រិតឥណទានសម្រាប់ផ្តល់ជូនអាជីវករ ពាណិជ្ជករ ផលិតករ អ្នកផ្តល់សេវាកម្ម និងអ្នកជំនួញស្របច្បាប់គ្រប់ប្រភេទ ជារូបវន្តបុគ្គល ឬនីតិបុគ្គល អាចដកប្រាក់តាមតម្រូវការពីគណនីចរន្តលើសពីសមតុល្យទឹកប្រាក់ដែលមានដាក់ស្តែងក្នុងគណនី (សមតុល្យឥណាយិក ឬសមតុល្យអវិជ្ជមាន) ។

ឥណទានវិបារូបន៍ ផ្តល់ជូនអតិថិជនជារូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ប្រាក់រៀល និងប្រាក់បាតទៅតាមតម្រូវការរបស់អតិថិជន។

☞**ការសងប្រាក់ធ្វើដោយស្វ័យប្រវត្តិ៖**

-ប្រាក់ដើមៈ ដក-ដាក់ប្រាក់ក្នុងគណនី ដូចការប្រើប្រាស់គណនីទូទៅ ។

-ការប្រាក់ៈ សងរៀងរាល់ចុងខែ។

-ករណីអតិថិជនមិនបានដាក់ប្រាក់ចូលគណនីការប្រាក់ដែលត្រូវសងនឹងត្រូវបានកាត់ចេញពីកម្រិតឥណទានដោយស្វ័យប្រវត្តិ ។

ឥណទានវិបារូបន៍សម្រាប់អ្នកលក់រាយ (Retail-Trader Overdraft or Trader-OD) គឺជាផ្នែកមួយនៃឥណទានវិបារូបន៍ របស់ធនាគារសហពាណិជ្ជ ក.អ ដោយអនុញ្ញាតឱ្យអ្នកខ្ចីដកប្រាក់លើសពីសមតុល្យទឹកប្រាក់ដែលអតិថិជនមានដាក់ស្ដែង ក្នុងគណនីបញ្ញើសំចៃ (សមតុល្យឥណាឃិក ឬសមតុល្យអវិជ្ជមាន) ក្នុងបរិមាណមួយមិនលើសពីការកំណត់ដែលបានព្រមព្រៀងនឹងត្រូវបង់ការប្រាក់លើទឹកប្រាក់ដែលបានដកលើសនោះជូនធនាគារវិញ។

ដើម្បីទទួលបានឥណទានវិបារូបន៍សម្រាប់អ្នកលក់រាយ អតិថិជនត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

**ជានីតិជន** (បុគ្គលដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ) យល់ព្រមប្រតិបត្តិតាមលក្ខខណ្ឌនៃឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ ។ មានកេរ្តិ៍ឈ្មោះល្អ អត្តចរិតល្អ ប្រវត្តិល្អ នឹងមានចេតនាសងបំណុល។ មានមុខរបរនឹងប្រភពចំណូលច្បាស់លាស់ មាននិរន្តរភាពដែលបង្ហាញពីសមត្ថភាពនិងលទ្ធភាពសងបំណុលត្រឡប់មកវិញ។មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ មានទីលំនៅអចិន្ត្រៃយ៍ដែលបញ្ជាក់ពីអាជ្ញាធរក្នុងតំបន់ដែលខ្លួនកំពុងរស់នៅ ឬមានលំនៅឋាននឹងទីកន្លែងស្នាក់នៅដែលមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។ មិនមានបំណងផ្លាស់ប្ដូរទីលំនៅឬទីកន្លែងស្នាក់នៅទៅកន្លែងផ្សេងស្ថិតនៅក្រៅតំបន់ប្រតិបត្តិការរបស់ធនាគារ សហពាណិជ្ជ ក.អ ដែលខ្លួនបានជំពាក់បំណុលរហូត ដល់ពេលសងបំណុលចប់។

### ច. ឥណទានពាណិជ្ជកម្ម

ឥណទានពាណិជ្ជកម្ម (Trade Finance Facility or " TFF " ) ជាឥណទានមួយប្រភេទ ត្រូវបានបង្កើតឡើងសម្រាប់ជួយបំពេញរាល់តម្រូវការហិរញ្ញប្បទានពីសំណាក់អតិថិជនគ្រប់មជ្ឈដ្ឋាន ដើម្បីទ្រទ្រង់ដល់ដំណើរការទូទាត់ថ្លៃទំនិញនាំចូល ឬនាំចេញស្របច្បាប់គ្រប់ប្រភេទរួមមាន វត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច នឹង ផលិតផលសម្រេច ។

ឥណទានពាណិជ្ជកម្មទំហំឥណទានដែលត្រូវដកទូទាត់ពាណិជ្ជកម្មអតិបរមាស្មើនឹងទំហំទឹកប្រាក់ដែលត្រូវចំណាយដូចមានកត់ត្រាជាក់លាក់នៅក្នុងវិក្កយបត្រពាណិជ្ជកម្ម ឬឯកសារចំណាយផ្សេងៗទៀតដែលស្ថិតក្រោមបទដ្ឋានអនុវត្តនៃពាណិជ្ជកម្មអន្តរជាតិ។ ទំហំទឹកប្រាក់សរុបបូកបញ្ចូលគ្នានៃឥណទានទូទាត់នីមួយៗ នឹងការជានាផ្សេងទៀត(បើមាន) មិនត្រូវលើសពីកម្រិតឥណទានដែលបានផ្ដល់ជូន លើកលែងតែមានការសម្រេចផ្ដល់ជូនបន្ថែមកម្រិតឥណទានផ្សេងទៀតសម្រាប់គាំទ្រ។ កម្រិតធានាលើលិខិតឥណទានទំហំកម្រិតធានាសម្រាប់ធានាដល់ការចេញលិខិតឥណទាន អតិបរមាស្មើនឹងទំហំទឹកប្រាក់ត្រូវទូទាត់ដូចមានកត់ត្រាជាក់លាក់នៅក្នុងវិក្កយបត្រ ឬកិច្ចសន្យាពាណិជ្ជកម្ម ឬចំនួនលំអៀង ស្ថិតក្រោមបទដ្ឋានកំណត់នៃពាណិជ្ជកម្ម

អន្តរជាតិ ឬតាមសំណើសុំជាលាយលក្ខអក្សររបស់អតិថិជន "ករណីចាំបាច់មិនមានវិក្កយបត្រ ឬកិច្ចសន្យាពាណិជ្ជកម្ម"។ ទំហំទឹកប្រាក់សរុបបូកបញ្ចូលគ្នានៃកម្រិតធានានីមួយៗ នឹងឥណទានទូទាត់ផ្សេងទៀត"បើមាន" មិនត្រូវលើសពីកម្រិតឥណទានដែលបានផ្ដល់ជូន លើកលែងតែមានការសម្រេចផ្ដល់ជូនបន្ថែមកម្រិតឥណទានផ្សេងទៀតសម្រាប់គាំទ្រ។

ដើម្បីអាចទទួលបានឥណទានពាណិជ្ជកម្មនេះ អតិថិជនត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

☞សម្រាប់នីតិបុគ្គល

- ជាក្រុមហ៊ុនមានទីតាំងស្ថិតនៅក្នុងប្រទេសកម្ពុជា។
- ជាក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះល្អហើយប្រវត្តិនៃមុខជំនួញមានស្ថេរភាពល្អប្រកបដោយស្ថានភាពរឹងមាំលើវិស័យហិរញ្ញវត្ថុអាចផ្ទៀងផ្ទាត់បាន។
- ជាក្រុមហ៊ុនដែលបានចុះបញ្ជីនឹងមានអាជ្ញាប័ណ្ណត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ជាក្រុមហ៊ុនដែលរក្សាបាននូវបរិស្ថាន ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ជាក្រុមហ៊ុនមានស្ថានភាពជំនួញល្អនៅក្នុងទីផ្សារ នឹងមានទំនាក់នងល្អជាមួយអតិថិជន។
- ជាក្រុមហ៊ុនមានលំហូរសាច់ប្រាក់នឹងនរ មានរបាយការណ៍ហិរញ្ញវត្ថុអាចទទួលយកបាន។

☞ **សម្រាប់រូបវន្តបុគ្គល** (បុគ្គលដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់)

- មានទីលំនៅអចិន្ត្រៃយ៍ច្បាស់លាស់ក្នុងតំបន់ប្រតិបត្តិការក្នុងរយៈពេលចុះកិច្ចសន្យាឥណទានជាមួយធនាគារ សហពាណិជ្ជ ក.អ ។
- ត្រូវមានសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬលិខិតផ្សេងៗទៀតដែលអាចជំនួសបាន។
- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ។
- មានគម្រោងជំនួញច្បាស់លាស់ដែលបង្ហាញថាមុខរបរមានសក្តានុពលមានប្រាក់ចំណេញនឹងមាននិរន្តរភាព។
- ផ្តល់ឯកសារច្បាប់អាជីវកម្ម និងឯកសារដទៃទៀត ប្រសិនបើមាន។
- មានលំហូរសាច់ប្រាក់នឹងនរ និងមានបញ្ជីស្នាមកត់ត្រាត្រឹមត្រូវ។
- មានស្ថានភាពជំនួញល្អនៅក្នុងទីផ្សារ និងមានទំនាក់ទំនងល្អជាមួយអតិថិជន។

### ៣.២.២ នីតិវិធីក្នុងការផ្តល់ឥណទាន

នីតិវិធីក្នុងការផ្តល់ឥណទានមាន៧តំណាក់កាលដូចជាៈ

❖ **ដំណាក់កាលទី១៖** ការទទួលស្វាគមន៍អតិថិជន ភ្នាក់ងារឥណទាន បេឡាករ ឬរដ្ឋបាល ត្រូវអនុវត្តៈ

- អញ្ជើញអតិថិជនអង្គុយកន្លែងសមរម្យ
- សាកសួរពីគោលបំណងដែលគាត់ត្រូវការ
- ពន្យល់ពីក្រុមហ៊ុន ពីឥណទាន នឹងវិធីសងប្រាក់ត្រឡប់មកវិញ
- សាកសួរពីប្រវត្តិ នឹងមុខរបរអតិថិជន
- ប្រាប់អតិថិជនពីតម្រូវការឯកសារ ID

ចំពោះអតិថិជនដែលមានលក្ខណអាចផ្តល់ឥណទានបាន យើងត្រូវបន្តដល់ដំណាក់កាលទី២។

❖ **ដំណាក់កាលទី២៖** ការបំពេញពាក្យស្នើសុំឥណទាន

- រៀបចំបំពេញពាក្យជូនអតិថិជន(បំពេញចូលគ្រប់ទម្រង់ទាំងអស់)ថតចម្លងអត្តសញ្ញាណប័ណ្ណនិងឯកសារផ្សេងៗ
- ទំនាក់ទំនងសួរភ្នាក់ងារឥណទានក្នុងការកំណត់ជួបអតិថិជន
- កំណត់ពេលវេលាជាមួយអតិថិជនក្នុងការជួបដល់លំនៅដ្ឋានឬទីកន្លែងប្រកបអាជីវកម្មដែលភ្នាក់ងារឥណទានចាំបាច់ចុះត្រួតពិនិត្យ

អ្នកទទួលពាក្យ ត្រូវថ្លែងអំណរគុណដល់អតិថិជនពីការផ្តល់សេវាកម្ម រួចបញ្ជូនពាក្យដែលបានបំពេញរួចដល់ភ្នាក់ងារឥណទានដែលទទួលខុសត្រូវផ្នែកប្រតិបត្តិការ។

❖ **ដំណាក់កាលទី៣៖** ការចុះអង្កេតនឹងវាយតម្លៃអតិថិជន។ ភ្នាក់ងារឥណទានចុះសាកសួរអ្នករស់នៅជិតខាងអតិថិជនដោយមិនបង្ហាញពីគោលបំណង ឬសមាសភាពពិតប្រាកដក្នុងគោលបំណងទទួលបានព័ត៌មានពិតពីអតិថិជន។ បន្ទាប់មកភ្នាក់ងារឥណទានត្រូវអនុវត្តៈ

- ជួបអតិថិជនតាមការណាត់ជួប
- ពិនិត្យសកម្មភាពមុខរបរ នឹងទ្រព្យសម្បត្តិដាក់បញ្ចាំរបស់អតិថិជន
- ធ្វើគំរោងជំនួញតាមសភាពជាក់ស្តែងនៃមុខរបររបស់អតិថិជន
- ស្នើសុំអតិថិជនដាក់លិខិតសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើមដំកល់ទុក នឹងចេញបង្កាន់ដៃដាក់ដំកល់ប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិជូនអតិថិជន
- ចុះជួបអ្នកធានា ដើម្បីពិនិត្យស្ថានភាពដែលអាចធានាបាន
- ពន្យល់អ្នកធានាពីការទទួលខុសត្រូវរបស់គាត់
- សាកសួរអ្នកធានាបន្ថែមពីទំនាក់ទំនងជាមួយអតិថិជន
- សាកសួរព័ត៌មានបន្ថែមពីសាច់ញាតិ អ្នកផ្គត់ផ្គង់ និងអតិថិជនរបស់គាត់
- បញ្ចប់ការបំពេញពាសន្លឹកចុងក្រោយនៃពាក្យស្នើសុំឥណទាន
- វិភាគនិងផ្ទៀងផ្ទាត់ព័ត៌មានទទួលបានតាមប្រភពផ្សេងៗ
- វាយតម្លៃពាក្យស្នើសុំឥណទាននូវចំណុចមួយចំនួនដូចជា ប្រវត្តិអតិថិជន ប្រវត្តិនៃការសងត្រឡប់វគ្គមុន (អតិថិជនចាស់ ) លក្ខណៈអត្តចរិតរបស់អតិថិជន នឹង គោលបំណងនៃការប្រើប្រាស់
- វាយតម្លៃលទ្ធភាពសងពីផលចំណេញលើមុខរបររបស់អតិថិជនពិនិត្យកម្រិតជីវភាពរស់នៅ នឹងទំហំទ្រព្យសម្បត្តិទាំងអស់របស់អតិថិជន
- ពិនិត្យលើទ្រព្យធានាបំណុល នឹងអ្នកធានាបំណុល
- វាយតម្លៃលើស្ថានភាពទីផ្សារលើមុខរបររបស់អតិថិជន ការប្រែប្រួលសេដ្ឋកិច្ច និងនយោបាយ។

❖ **ដំណាក់កាលទី៤៖** ការអនុម័តឥណទានៈ ប្រធានផ្នែកឥណទានត្រូវសង្ខេបព័ត៌មានអំពីអតិថិជនជូនសមាជិកគណកម្មាធិការឥណទាន រួចស្នើសុំយោបល់ពីសមាជិកគណកម្មាធិការឥណទាន។ បន្ទាប់មកគណកម្មាធិការឥណទានប្រចាំសាខាបានផ្តល់យោបល់លើសំណើរសុំអនុម័តឥណទាន មាន២ករណីគឺ ៖

- ករណីទី១ គឺការបដិសេធ ការស្នើសុំឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា រក្សាទុកឯកសារមិន បានអនុម័តរួចផ្តល់ចម្លើយទៅភ្នាក់ងារ។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយដោយបដិសេធ សំណើរសុំឥណទានទៅកាន់អតិថិជន នឹងរៀបចំដកប័ណ្ណសំគាល់កម្មសិទ្ធិជូនអតិថិជនវិញ។
- ករណីទី២ គឺយល់ព្រមអនុម័តឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា ត្រូវផ្តល់ចម្លើយទៅអោយភ្នាក់ងារឥណទាន។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយយល់ព្រមអនុម័តឥណទាន ជូនអតិថិជន។

❖ **ដំណាក់កាលទី៥៖** ការរៀបចំឯកសារឥណទាន ។ ភ្នាក់ងារឥណទានត្រូវអនុវត្តៈ

- រៀបចំកិច្ចសន្យាខ្ចីប្រាក់ នឹងកិច្ចសន្យាដាក់បញ្ចាំ រួចផ្ទេរសិទ្ធិគ្រប់គ្រងនឹងយល់ព្រមលក់ទ្រព្យបញ្ចាំ

អានពន្យល់ឱ្យបានច្បាស់លាស់ជូនអតិថិជន និងអ្នកធានា ស្តាប់មុនផ្តិតមេដៃ

- អតិថិជន និងអ្នកធានាតម្រូវឱ្យផ្តិតមេដៃនៅចំពោះមុខលើកិច្ចសន្យាទាំងអស់ នឹងអត្តសញ្ញាណប័ណ្ណ ថតចម្លងរួមទាំងចុះកាលបរិច្ឆេទផងដែរ
- ស្នើឱ្យអតិថិជន យកឯកសារទៅបញ្ជាក់នៅអាជ្ញាធរមូលដ្ឋាន
- ប្រសិនបើអតិថិជនត្រូវការដកប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើម ស្នើសុំបង្កាន់ដៃដាក់ដំកល់ដើម្បី ឱ្យអតិថិជនផ្តិតមេដៃ
- បន្ទាប់មកអតិថិជនត្រូវបញ្ជូនឯកសារឥណទានត្រឡប់មកវិញរួចហើយភ្នាក់ងារឥណទានត្រូវ
  - ➢ ពិនិត្យកិច្ចសន្យាទទួលពីអតិថិជនទាំងអស់ឡើងវិញនឹងថតចម្លងមួយច្បាប់សម្រាប់អតិថិជន កំណត់
  - ➢ កំណត់ពេលបញ្ចេញសាច់ប្រាក់ ទីកន្លែងទទួលប្រាក់ ឱ្យអតិថិជនភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណ ច្បាប់ដើមនៅពេលទទួលប្រាក់
  - ➢ ស្នើសុំរដ្ឋបាលធ្វើតារាងសងរំលស់ប្រាក់ នឹងដាក់ប្រាក់សន្សំពីរច្បាប់
  - ➢ រៀបចំសៀវភៅតាមដានការសងប្រាក់ និងការសន្សំប្រាក់សម្រាប់អតិថិជន ដោយចុះកត់ត្រាចំនួនខ្ចី នឹង សមតុល្យប្រាក់សន្សំឱ្យបានច្បាស់លាស់
  - ➢ បញ្ជូនឯកសារទាំងអស់ទៅប្រធានផ្នែកឥណទានប្រចាំសាខា
- បន្ទាប់មកប្រធានផ្នែកឥណទានប្រចាំសាខា ពិនិត្យផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃឯកសារទាំងអស់ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយប្រធានផ្នែកឥណទានប្រចាំសាខាត្រូវចុះហត្ថលេខាលើ Checklist
- បន្ទាប់ពីចុះហត្ថលេខារួចហើយ ត្រូវបញ្ជូនមកកាន់រដ្ឋបាលសាខា។ រដ្ឋបាលសាខាពិនិត្យផ្ទៀងផ្ទាត់ ពីភាពត្រឹមត្រូវគ្រប់គ្រាន់នៃឯកសារទាំងអស់ ( ប្រសិនបើពិនិត្យ ផ្ទៀងផ្ទាត់ហើយឃើញថាមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវនោះទេ រដ្ឋបាលសាខាបញ្ជូនមកកាន់ប្រធានផ្នែកឥណទានប្រចាំសាខា ហើយ ប្រធានផ្នែកឥណទានប្រចាំសាខា ត្រូវបញ្ជូនមកកាន់ភ្នាក់ងារឥណទានវិញដើម្បីឱ្យភ្នាក់ងារឥណទាន ត្រួតពិនិត្យ នឹងរៀបចំឯកសារ សារឡើងវិញ។ ប្រសិនបើរដ្ឋបាលពិនិត្យឃើញថាឯកសារគ្រប់គ្រាន់នឹង ត្រឹមត្រូវហើយនោះ រដ្ឋបាលត្រូវចុះហត្ថលេខាលើ Checklist)
- បន្ទាប់ពីរដ្ឋបាលចុះហត្ថលេខាលើ Checklist រួចហើយត្រូវបញ្ជូនទៅកាន់គណនេយ្យករសាខា។ គណនេយ្យករសាខាពិនិត្យ រៀបចំ Cash Disbursement Voucher (CDV)
- រួចបញ្ជូនទៅប្រធានសាខាចុះហត្ថលេខា នឹងបោះត្រាលើ Checklist and CDV
- បន្ទាប់មកបញ្ជូនឯកសារទៅបេឡាករសាខា ឬសាខារងដែលអតិថិជនត្រូវមកទទួល

❖ **ដំណាក់កាលទី៦៖** ការបញ្ចេញឥណទាន បេឡាករសាខាត្រូវអនុវត្ត ៖

- ពិនិត្យឈ្មោះ ផ្ទៀងផ្ទាត់រូបភាព (អតិថិជនមកទទួលប្រាក់) មុខអ្នកខ្ចីផ្ទាល់តែម្តង
- ស្នើសុំអតិថិជនផ្តិតមេដៃលើ CDV នឹងលើតារាងកាលវិភាគសងប្រាក់
- ជូនតារាងកាលវិភាគសងប្រាក់ នឹងដាក់ប្រាក់សន្សំទៅកាន់អតិថិជន ហើយពន្យល់ពីរបៀបអាននឹង របៀបគណនាក្នុងតារាងនោះ

- ជូនកិច្ចសន្យាថតចម្លងទៅកាន់អតិថិជន
- ពិនិត្យចំនួនខ្ចីនឹងសមតុល្យប្រាក់សន្សំនៅក្នុងសៀវភៅតាមដានការសងប្រាក់ ហើយពន្យល់ពីអត្ថប្រយោជន៍នៃសៀវភៅ នឹងការរក្សាសៀវភៅឱ្យបានល្អមុនពេលជូនទៅកាន់អតិថិជន
- រំលឹកពីគោលការណ៍សងប្រាក់ ថ្ងៃសងប្រាក់ ទីកន្លែង នឹងយកសៀវភៅតាមដានការសងប្រាក់ត្រឡប់មកវិញពេលទូទាត់ប្រាក់
- ផ្តល់ប្រាក់ដល់អតិថិជន
- ថ្លែងអំណរគុណអតិថិជនពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសហពាណិជ្ជ ក អ
- បេឡាករសាខា ឬសាខារង ត្រូវផ្តល់ឯកសារឥណទានដល់រដ្ឋបាលប្រចាំសាខាដើម្បីរក្សាទុក
- រដ្ឋបាលប្រចាំសាខាចុះក្នុងបញ្ជីតាមដានការប្រគល់នឹងដកប័ណ្ណសម្គាល់កម្មសិទ្ធិនូវទ្រព្យសម្បត្តិដែលបានទទួលពីបេឡាករ ឬភ្នាក់ងារឥណទាន
- រដ្ឋបាលប្រចាំសាខាឥណទាន រក្សាឯកសារឥណទានរបស់អតិថិជនជាមួយឯកសារឥណទានពីវគ្គមុនជាមួយគ្នា ( រួមគ្នា )

❖ **ដំណាក់កាលទី៧៖** ការតាមដានអតិថិជន ភ្នាក់ងារឥណទានដែលទាក់ទងត្រូវអនុវត្ត៖

- ចុះសួរសុខទុក្ខអតិថិជនមួយសប្តាហ៍យ៉ាងយូរបំផុត ក្រោយចេញឥណទាន នឹងតាមដានឱ្យបានទៀងទាត់ជារៀងរាល់មួយខែម្តងយ៉ាងតិចបំផុត
- សាកសួរពីការវិវត្តលើមុខរបរ
- សង្កេតមើលការប្រើប្រាស់ឥណទាន
- សរសេររបាយការណ៍សង្ខេបជូនទៅប្រធានផ្នែកឥណទានប្រចាំសាខា។

## ៣.៣ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព

ជាគំរូនៃវិធីសាស្ត្រក្នុងការប្រើប្រាស់ឧបករណ៍ធនធានផ្សេងៗដើម្បីកាត់បន្ថយនឹងគ្រប់គ្រងហានិភ័យដែលអាចកើតមានពីការផ្តល់ឥណទានទៅកាន់អតិថិជនឬអាជីវករ។វារួមបញ្ចូលដំណើរការជាច្រើនដែលមានគោលបំណងធានាថាការផ្តល់ឥណទានត្រូវបានអនុម័តនៅលើមូលដ្ឋាននៃសមត្ថភាពបង់ប្រាក់របស់អ្នកខ្ចីហើយកាត់បន្ថយបញ្ហាផលវិបាកនៃតម្រូវការសេដ្ឋកិច្ចរបស់ធនាគារ។ការវាយតម្លៃសមត្ថភាពឥណទាន (Credit Assessment) គឺជាដំណើរការសំខាន់មួយសម្រាប់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុដើម្បីប៉ាន់ប្រមាណសមត្ថភាពសងប្រាក់របស់អតិថិជន។ វាបង្កើតឡើងដើម្បីបញ្ជាក់ថាអតិថិជនអាចសងប្រាក់ឥណទានវិញបានត្រឹមត្រូវ ឬអាចមានហានិភ័យក្នុងបំណុល។

**☞ប្រភេទការវាយតម្លៃសមត្ថភាពឥណទាន:**

១. ការវាយតម្លៃលើអតិថិជនឯកជន **(Individual Credit Assessment):** គឺជាដំណើរការដែលធនាគារឬស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់ដើម្បីវាយតម្លៃសមត្ថភាពសន្តិសុខនៃការអនុម័តឥណទានឱ្យទៅអតិថិជនឯកជន វារួមបញ្ចូលការពិនិត្យអំពីប្រវត្តិឥណទាននឹងស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនដើម្បីបញ្ជាក់ថាពួកគេអាចបង់ប្រាក់ឥណទានវិញបានតាមពេលវេលាកំណត់។ ប្រវត្តិឥណទាន (Credit History) ពិនិត្យប្រវត្តិឥណទានរបស់អតិថិជន ដើម្បីត្រួតពិនិត្យថាតើ ពួកគេមានបង់ប្រាក់តាមកាលកំណត់រួមទាំងសកម្មភាពទាក់ទងនឹងការចាប់ផ្តើមឥណទានពីមុនយ៉ាងដូចម្តេច។ សមត្ថភាពចំណូល (Income Stability) ពិនិត្យចំណូលប្រចាំខែរបស់

អតិថិជនដើម្បីធានាថាពួកគេចាប់ផ្តើមមានសមត្ថភាពបង់ប្រាក់ឥណទាន។ ត្រូវពិនិត្យប្រភពចំណូលដែលមានស្ថេរភាព ដូចជា មុខរបរ ឬការងារដែលអតិថិជនធ្វើ។ ឯកសារផ្ទាល់ខ្លួន (Personal Documents) ត្រូវការអតិថិជនផ្តល់ឯកសារផ្ទាល់ខ្លួនដូចជា អត្តសញ្ញាណប័ណ្ណ ប័ណ្ណចុះបញ្ជីគ្រួសារ និងប័ណ្ណប្រកបអាជីវកម្ម (ប្រសិនបើមាន) ដើម្បីបញ្ជាក់ពីអត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួន។

២. ការវាយតម្លៃលើអាជីវកម្ម **(Business Credit Assessment):** គឺជាការវាយតម្លៃសមត្ថភាពរបស់អាជីវកម្មមួយក្នុងការបង់ប្រាក់ឥណទាន។ ដំណើរការនេះធ្វើឡើងដើម្បីពិនិត្យថា អាជីវករមានសមត្ថភាពលើការគ្រប់គ្រងឥណទាន នឹងបំណុលដែលបានខ្ចីដែរឬទេ។ ឧទាហរណ៍ស្ថានភាពហិរញ្ញវត្ថុ (Financial Statements) ប្រវត្តិអាជីវកម្មនឹងទីផ្សារ (Business History & Market Position) សមត្ថភាពបង់ប្រាក់ (Repayment Ability) កាលវិភាគ នឹងវិធីសាស្ត្រវាយតម្លៃ។

៣. ការកំណត់លក្ខខណ្ឌទូទាត់ **(Payment Terms):** ការកំណត់លក្ខខណ្ឌទូទាត់ដែលច្បាស់លាស់ សមស្រប ដើម្បីធានាការទូទាត់ត្រឹមត្រូវ នឹងទៀងទាត់ពីអតិថិជន។ការធានារ៉ាប់រងឥណទាន (Credit Insurance) ប្រើប្រាស់សេវារ៉ាប់រងការបង់បំណុលក្នុងករណីអតិថិជនមិនអាចបង់បាន ដើម្បីការពារការខាតបង់ហិរញ្ញវត្ថុ។

៤. ការពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យ (Risk Management Systems): ប្រើប្រាស់បច្ចេកវិទ្យាដើម្បីបញ្ជាការគ្រប់គ្រងហានិភ័យឥណទានឱ្យមានស្ថេរភាព នឹងប្រកបដោយប្រសិទ្ធភាព។ ការបង្កើតគោលការណ៍ឥណទានច្បាស់លាស់ (Clear Credit Policies) មានគោលការណ៍ឥណទានដែលច្បាស់លាស់នឹងត្រឹមត្រូវ ដើម្បីណែនាំបុគ្គលិកក្នុងការផ្តល់ឥណទាននឹងការគ្រប់គ្រងហានិភ័យ។

**៣.៣.១ គណៈកម្មការគ្រប់គ្រងហានិភ័យ**

គណៈកម្មការគ្រប់គ្រងហានិភ័យ **(Risk Management Committee)** គឺជាក្រុមអ្នកដែលមានភារកិច្ចក្នុងការកំណត់ នឹងគ្រប់គ្រងហានិភ័យដែលអាចកើតមាននៅក្នុងអង្គភាព ឬក្នុងក្រុមហ៊ុនមួយ។ គណៈកម្មការនេះមានតួនាទីក្នុងការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយដែលត្រូវធ្វើដើម្បីកាត់បន្ថយនឹងគ្រប់គ្រងហានិភ័យជាច្រើនដែលអាចប៉ះពាល់ដល់សកម្មភាពរបស់អាជីវកម្ម។

**☞តួនាទីនឹងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងហានិភ័យ:**

១. កំណត់គោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ: បង្កើតគោលនយោបាយ នឹងយុទ្ធសាស្ត្រដែលផ្អែកលើការវាយតម្លៃហានិភ័យដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានឡើង។សម្គាល់នឹងវាយតម្លៃហានិភ័យ កំណត់ប្រភេទហានិភ័យដែលអាចប៉ះពាល់ដល់ធនាគារដូចជា ហានិភ័យហិរញ្ញវត្ថុ (financial risk) ហានិភ័យប្រតិបត្តិការ (operational risk) ហានិភ័យទីផ្សារ (market risk) និងហានិភ័យផ្លូវច្បាប់ (compliance risk)។

២. ការត្រួតពិនិត្យ និងការតាមដាន: តាមដានប្រតិបត្តិការនានាដើម្បីធានាថាបានអនុវត្តតាមគោលការណ៍គ្រប់គ្រងហានិភ័យ នឹងធ្វើការកែសម្រួលឱ្យបានត្រឹមត្រូវ។ ការបណ្តុះបណ្តាលបុគ្គលិក ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអំពីការគ្រប់គ្រងហានិភ័យ នឹងវិធានការដែលត្រូវអនុវត្ត។ ការបង្កើតវប្បធម៌គ្រប់គ្រងហានិភ័យលើកកម្ពស់វប្បធម៌នៃការយល់ដឹង និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យទូទាំងស្ថាប័ន។

៣. ការប្រើប្រាស់បច្ចេកវិទ្យា: អនុវត្តប្រព័ន្ធបច្ចេកវិទ្យា ដើម្បីជួយក្នុងការតាមដាន ការវាយតម្លៃ

ហានិភ័យ។ ការបង្កើតផែនការឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតមានដើម្បីកាត់បន្ថយផលប៉ះពាល់នានា។ ការផ្តល់របាយការណ៍ ការរៀបចំរបាយការណ៍អំពីស្ថានភាពហានិភ័យ នឹងការគ្រប់គ្រងហានិភ័យដើម្បីជូនដំណឹងដល់គណៈកម្មការគ្រប់គ្រង នឹងភាគីពាក់ព័ន្ធ។

៤. ការបង្កើតប្រព័ន្ធសំរាប់ឆ្លើយតបហានិភ័យអាសន្នៈ រៀបចំផែនការការងារ នឹងវិធានការចាំបាច់ដើម្បីទទួលស្គាល់ នឹងដោះស្រាយហានិភ័យអាសន្នដែលអាចកើតមានឡើង។ ការពិនិត្យឡើងវិញនូវគោលនយោបាយ នឹងដំណើរការគ្រប់គ្រងហានិភ័យធ្វើការពិនិត្យ ធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ នឹងដំណើរការគ្រប់គ្រងហានិភ័យដើម្បីធានាថាសមស្របទៅនឹងស្ថានភាពបច្ចុប្បន្នដែរឬទេ។ការបង្កើតប្រព័ន្ធរាយការណ៍ហានិភ័យគឺជាការបង្កើតប្រព័ន្ធសម្រាប់បុគ្គលិករាយការណ៍អំពីហានិភ័យឬបញ្ហាដែលពួកគេបានសង្កេតឃើញ ដើម្បីអនុវត្តវិធានការឱ្យបានត្រឹមត្រូវ។

៥. ការសហការជាមួយអង្គភាពផ្សេងៗ: ធ្វើការជាមួយអង្គភាពផ្សេងៗក្នុងស្ថាប័ន ដើម្បីធានាថាការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហានិភ័យ ធ្វើការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហានិភ័យដើម្បីកំណត់ប្រសិទ្ធភាព នឹងសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យ។

៦. ការផ្តល់សេចក្តីណែនាំ និងការគាំទ្រដល់ការគ្រប់គ្រង: ផ្តល់សេចក្តីណែនាំ នឹងគាំទ្រដល់ការគ្រប់គ្រងដើម្បីធានាថាការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តតាមគោលការណ៍យុទ្ធសាស្ត្រដែលបានកំណត់ដែរឬទេ។

**៣.៣.២ វាស់វែងហានិភ័យឥណទាន**

សកម្មភាពសំខាន់មួយក្នុងការគ្រប់គ្រងហានិភ័យជាមួយអតិថិជនឥណទានដែលធានាថា ហានិភ័យដែលអាចប៉ះពាល់ដល់ស្ថេរភាពហិរញ្ញវត្ថុរបស់ធនាគារត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។ ក្នុងការវាស់វែងហានិភ័យឥណទាននេះ ធនាគារសហពាណិជ្ជ ក.អ ប្រើប្រាស់វិធីសាស្ត្រជាច្រើនដូចជា:

**ក. ការវាយតម្លៃប្រវត្តិឥណទានៈ** ធនាគារអនុវត្តការវាយតម្លៃប្រវត្តិឥណទានដើម្បីវាស់សមត្ថភាពក្នុងការបង់ប្រាក់របស់អតិថិជន។ប្រវត្តិឥណទានរបស់អតិថិជនធ្វើឱ្យធនាគារបង្ហាញថាអតិថិជនមានសមត្ថភាពក្នុងការបង់ប្រាក់ទាន់ពេលវេលាដែលបានកំណត់ មិនឱ្យប៉ះពាល់ដល់កម្ចីទាំងអស់។

**ខ. ការវាយតម្លៃសមត្ថភាពស្នើសុំឥណទានៈ** ធនាគារត្រូវការពិនិត្យសមត្ថភាពរបស់អតិថិជនដូចជាការពិនិត្យប្រាក់ចំណូល នឹងបំណុលផ្សេងៗ។ ធនាគារប្រើកម្រិតដែលអាចឱ្យអ្នកខ្ចីឥណទានសម្របសម្រួលជាមួយសភាពការសេដ្ឋកិច្ច នឹងទិន្នន័យការលក់។

**គ. ការប្រើប្រាស់គំរូសម្រាប់វាយតម្លៃហានិភ័យៈ** ធនាគារប្រើប្រាស់គំរូវិភាគប្រភេទហានិភ័យដូចជាសេចក្តីព្រាងហានិភ័យ (Credit Scoring Model) ដែលគឺជាបច្ចេកទេសជួយវាស់វែងលើប្រវត្តិឥណទាននឹងសមត្ថភាពរបស់អតិថិជនក្នុងការបង់ប្រាក់។ បច្ចេកទេសនេះអាចស្វែងរកនូវហានិភ័យដែលអាចកើតមានផ្តល់អត្ថប្រយោជន៍សំរាប់ការបញ្ជាក់លើការផ្តល់ឥណទាន។

**ឃ. ការអនុវត្ត ការវាយតម្លៃគោលការណ៍រួមផ្សំៈ** ធនាគារអនុវត្តការវាស់វែងហានិភ័យឥណទានដោយចាប់ផ្តើមជាមួយវិធីសាស្ត្រជាច្រើនដែលគ្របដណ្តប់លើការវាស់វែងដូចជាបន្ថែមអត្រាពីហានិភ័យនឹងការវាយតម្លៃផលប៉ះពាល់នៃជួរឈរ។

**ង. ការវាយតម្លៃអត្រាអន្តរជាតិក្នុងការបង់ប្រាក់៖** អនុវត្តការវាស់វែងតម្រូវឱ្យធនាគារពិនិត្យការជំរុញប្រាក់កម្ចីឥណទាន ដែលពាក់ព័ន្ធជាមួយសេដ្ឋកិច្ចសហព័ន្ធ នឹងអត្រាការប្រាក់នៅលើទីផ្សារ។ វាអាចត្រូវការប្រើប្រាស់តម្លៃបរិមាណនៃហានិភ័យដើម្បីត្រួតពិនិត្យជាបន្តបន្ទាប់។

**៣.៣.៣ គ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ**(CEL)

❖ **គ្រប់គ្រងកម្រិតហានិភ័យ**

ដំណើរការដែលធនាគារប្រកួតប្រជែងក្នុងការវាស់វែងនឹងបញ្ជាក់កម្រិតហានិភ័យដើម្បីធានាថាការធ្វើប្រតិបត្តិការប្រកួតប្រជែងត្រូវបានគ្រប់គ្រងនឹងធានាថាមានសុវត្ថិភាពទាំងក្នុងការផ្តល់ឥណទាននឹងដំណើរការផ្សេងៗ។ ជាទូទៅការគ្រប់គ្រងកម្រិតហានិភ័យនៅក្នុងធនាគារសហពាណិជ្ជ ក.អ ត្រូវតែមើលបញ្ហាជាចម្បងដូចជា៖

**១. ការសម្គាល់និងការវាស់វែងហានិភ័យ៖** ធនាគារសហពាណិជ្ជ ក.អ សម្គាល់ហានិភ័យដែលអាចប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារដូចជា ហានិភ័យឥណទាន (Credit Risk) ហានិភ័យដែលអ្នកខ្ចីមិនអាចបង់ប្រាក់តាមពេលវេលានៅក្នុងកិច្ចសន្យា។ ហានិភ័យបរិស្ថាន (Market Risk) ឧទាហរណ៍ការផ្លាស់ប្តូរអត្រាការប្រាក់ ឬវិនិយោគ។ ហានិភ័យតុល្យភាព (Liquidity Risk) ហានិភ័យដែលធនាគារមិនអាចដោះសោរប្រាក់បានគ្រប់ពេលវេលា។

**២. ការកំណត់គោលនយោបាយការគ្រប់គ្រង៖** ធនាគារត្រូវបានកំណត់គោលនយោបាយ ការគ្រប់គ្រងហានិភ័យដើម្បីបង្កើតក្រមវិធានការសំរាប់ការសម្រេចចិត្ត។ គោលនយោបាយនេះអាចរួមមាន ការគ្រប់គ្រងឥណទាន ដំណើរការបញ្ចេញឥណទាន ត្រូវតែមានការពិនិត្យយ៉ាងល្អិតល្អន់ពីអ្នកខ្ចីនឹងតម្រូវការប្រាក់។

**៣. ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុជាបច្ចេកវិទ្យា៖** ធនាគារប្រើប្រាស់ប្រព័ន្ធទិន្នន័យឧត្តមដោយការប្រើប្រាស់ស្ថាប័នកំណត់ទិន្នន័យពាក់ព័ន្ធដូចជា Credit Scoring System ឬទិន្នន័យការអនុម័តកម្ចី។ បច្ចេកទេសនេះអាចជួយក្នុងការគ្រប់គ្រងបរិមាណហានិភ័យប្រើប្រាស់។

**៤. ការអនុវត្ត ការបញ្ជាក់ ការប្រកួតប្រជែង៖** ធនាគារអនុវត្តការបញ្ជាក់ ការប្រកួតប្រជែងដោយការពិនិត្យនូវការបញ្ចូលឥណទានជាមួយប្រព័ន្ធហិរញ្ញវត្ថុ នឹងគ្រប់គ្រងជម្រើសប្រព័ន្ធបច្ចេកវិទ្យា។

ឧទាហរណ៍៖ ការផ្តល់ឥណទានប្រហែល ៨០% ទៅ ៩០% ក្នុងការប្រាក់ផ្សេងៗ។

**៥. ការគ្រប់គ្រងសុខភាពហិរញ្ញវត្ថុ៖** ធនាគារត្រូវការតាមដានបច្ចេកទេសផ្លូវការហិរញ្ញវត្ថុ ដោយការត្រួតពិនិត្យការប្រាក់និងការពិនិត្យសុខភាពហិរញ្ញវត្ថុ។ ការបញ្ចូលទិន្នន័យដែលត្រូវតែជួយគ្រប់គ្រងអត្រាការប្រាក់ និងវិនិយោគសម្រាប់ការផ្លាស់ប្តូរផ្សេងៗនៃហានិភ័យ។

❖ **គោលការណ៍បន្ថយហានិភ័យ(CEL)**

គោលការណ៍បន្ថយហានិភ័យ (CEL) របស់ធនាគារសហពាណិជ្ជ ក.អ គឺជាការអនុវត្តដែលមានគោលបំណងដើម្បីបន្ថយហានិភ័យក្នុងការផ្តល់ឥណទាន ឬកម្ចីនៅក្នុងធនាគារ។ CEL ឬ Credit Exposure Limit ត្រូវបានប្រើប្រាស់ក្នុងការកំណត់កម្រិតនៃការប្រាក់ ឬកម្ចីដែលធនាគារអាចផ្តល់ឱ្យអតិថិជននីមួយៗ ឬអាជីវកម្មនីមួយៗ ដើម្បីការពារហានិភ័យក្នុងករណីដែលមានការមិនអាចបង់ប្រាក់បាន។ វាជាដំណោះស្រាយសម្រាប់ការគ្រប់គ្រងហានិភ័យឥណទាន។

១. ការបញ្ជាក់កម្រិតឥណទាន (Credit Exposure Limit) CEL ជាកម្រិតនៃការផ្តល់ឥណទាន ឬកម្ចី ដែលធនាគារអាចឱ្យអតិថិជនម្នាក់ ឬអាជីវកម្មមួយ។ CEL នេះធ្វើការបង្ហាញពីប្រភេទនៃការការពារហានិភ័យនៃការផ្តល់ឥណទាន។

២. ការត្រួតពិនិត្យចំពោះស្ថានភាពការបង់ប្រាក់នៅក្នុង CEL ធនាគារត្រូវតែធ្វើការត្រួតពិនិត្យពីស្ថានភាពបច្ចុប្បន្នរបស់អតិថិជនឬអាជីវកម្មនោះ។ ដើម្បីប៉ាន់ស្មានថា តើអតិថិជនអាចបង់ប្រាក់តាមកាលបរិច្ឆេទបានដែរឬទេ។ ការត្រួតពិនិត្យនេះអាចរួមមានការវាយតម្លៃលើប្រវត្តិឥណទាន នឹងសមត្ថភាពក្នុងការបង់ប្រាក់បំណុលដែលបានខ្ចី។

៣. ការចុះបញ្ជីនៃប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងធនាគារសហពាណិជ្ជក.អ មានប្រព័ន្ធនៃការចុះបញ្ជីនិងការអនុវត្តក្នុងការពិចារណាផ្តល់ឥណទានលើ CEL ដើម្បីធានាថាផលិតភាពល្អនៃការអនុវត្ត ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យការប្តូរលើការប្រើប្រាស់ CEL ជារឿយៗជាការពិចារណាពីលក្ខណៈទាំងនេះ។

៤. ការកំណត់ហានិភ័យក្នុងការផ្តល់ឥណទាន CEL មានគោលបំណងដើម្បីកំណត់កម្រិតហានិភ័យដែលអាចទទួលបានក្នុងការផ្តល់ឥណទាន។ គោលការណ៍នេះធ្វើការត្រួតពិនិត្យក្នុងការផ្តល់ឥណទានមួយដែលមានតម្រូវការផ្អែកលើបរិមាណ ប្រភេទនៃការប្រាក់ និងការប្រើប្រាស់ឥណទាន។

**៣.៣.៤ គុណភាពឥណទានទ្រព្យសកម្ម**

គុណភាពឥណទានទ្រព្យសកម្មត្រូវបានកំណត់ ដោយផ្អែកទៅលើចំណាត់ថ្នាក់របស់ភាគីដៃគូដែលត្រូវបានកំណត់ថាមានតម្លៃស្មើនឹងអត្រារបស់ភ្នាក់ងារវាយតម្លៃ ចំពោះថ្នាក់អន្តរជាតិផ្សេងៗដូចខាងក្រោម៖

- គុណភាពឥណទាន ពណ៌នា អធិបតេយ្យ សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលចេញដោយធនាគារកណ្តាល រដ្ឋាភិបាល ឬត្រូវបានធានាដោយធនាគារកណ្តាលរបស់រដ្ឋាភិបាល។

- ចំណាត់ថ្នាក់វិនិយោគ សំដៅដល់គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលអ្នកបោះផ្សាយមានលទ្ធភាពបំពេញកាតព្វកិច្ចសងបំណុល ហើយអ្នកកាន់កាប់សញ្ញាប័ណ្ណមានហានិភ័យឥណទានទាបចំពោះការមិនសងប្រាក់។

- មិនមានចំណាត់ថ្នាក់វិនិយោគសំដៅដល់គុណភាពឥណទានកម្រិតទាបនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការប្រឈមខ្ពស់នឹងហានិភ័យនៃការមិនសងប្រាក់។

- មិនមានចំណាត់ថ្នាក់សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបច្ចុប្បន្ននេះមិនមានចំណាត់ថ្នាក់ទេ អាស្រ័យដោយមិនមានគំរូចំណាត់ថ្នាក់។

- ថយចុះតម្លៃឥណទាន សំដៅដល់ទ្រព្យសកម្មដែលមានការថយចុះតម្លៃ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមក ទៅលើដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ រួចមកក្រុមយើងខ្ញុំបានមើលឃើញនូវចំណុចខ្លាំងមួយចំនួនដូចខាងក្រោម៖

- ធនាគារសហពាណិជ្ជ ក.អ បានដាក់ចេញនូវផលិតផលឥណទានរបស់ខ្លួនជាច្រើនប្រភេទរួមមាន៖ ឥណទានគេហដ្ឋាន ឥណទានវិនិយោគលើគេហដ្ឋាន ឥណទានកែលម្អគេហដ្ឋាន ឥណទានអាជីវកម្មខ្នាតតូច ឥណទានវិបារូបន៍ ឥណទានពាណិជ្ជកម្ម ព្រមជាមួយគ្នានេះដែរធនាគារក៏បានផ្តល់ជូននូវសេវាកម្មល្អនឹងរហ័សទាន់ចិត្ត ដែលអាចបំពេញតម្រូវការអតិថិជនបានភ្លាមៗផងដែរ។
- រាល់ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក.អ ត្រូវបានអនុវត្តទៅតាមដំណាក់កាលនីមួយៗ ក៏ដូចជាគោលនយោបាយក្នុងការផ្តល់ឥណទានដែលធនាគារបានកំណត់ឡើង។ បន្ថែមពីនេះទៅទៀត ធនាគារក៏បានដាក់ចេញនូវគោលនយោបាយក្នុងការរក្សាទុករាល់ឯកសារ ឬព័ត៌មានទាំងអស់របស់អតិថិជនទុកជាការសម្ងាត់។
- ទន្ទឹមនឹងនេះធនាគារផ្តល់ជូនអតិថិជននូវការប្រឹក្សាយោបល់ ជាមួយនឹងអ្នកជំនាញដើម្បីកាត់បន្ថយនូវហានិភ័យដែលកើតមាននៅក្នុងប្រតិបត្តិការអាជីវកម្ម ព្រមទាំងផ្តល់នូវដំណោះស្រាយល្អជូនដល់អតិថិជននៅពេលដែលឥណទានមានបញ្ហា។
- ធនាគារបានដាក់ចេញនូវគោលនយោបាយជាច្រើន ដើម្បីធ្វើការទប់ស្កាត់ព្រមទាំងកាត់បន្ថយនូវហានិភ័យឥណទាន ដែលកើតមានឡើងតាមរយៈការសិក្សាព្រមទាំងធ្វើការសន្និដ្ឋានដោយ ផ្អែកទៅលើ 5Cs 4Rs គោលនយោបាយក្នុងការផ្តល់ឥណទាននឹងបទពិសោធន៍នានា។
- ធនាគារបានចូលរួមចំណែកក្នុងការជួយឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើន ព្រមទាំងបានចូលរួមក្នុងការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសង្គម តាមរយៈការចាក់បញ្ចូលនូវឥណទាន ដែលមានអត្រាការប្រាក់ទាបក្នុងការជួយគាំទ្រដល់សាធារណជន សហគ្រាស ស្ថាប័នហិរញ្ញវត្ថុ អង្គភាពអាជីវកម្មដែលមានតម្រូវការសាច់ប្រាក់ក្នុងការចាប់ផ្តើម នឹងពង្រីកនូវអាជីវកម្មបានជាច្រើនវិស័យដូចជា ធនាគារ ហិរញ្ញវត្ថុ អចលនទ្រព្យ ទេសចរណ៍ ម្ហូបអាហារ បដិសណ្ឋារកិច្ច វាយនភ័ណ្ឌ កសិកម្ម ឧស្សាហកម្ម និងសំណង់...។ល។

## ៤.២ ការវិភាគលើចំណុចខ្សោយ

បន្ទាប់ពីបានរកឃើញនូវចំណុចខ្លាំងខាងលើរួចមក យើងក៏បានឃើញនូវចំណុចខ្វះខាតមួយចំនួនដែលចាត់ទុកជាចំណុចខ្សោយរបស់ធនាគារ ក្នុងការបម្រើអតិថិជនរួមមាន៖

- នៅក្នុងដំណើរការនៃការស្នើសុំឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ ទៅលើផលិតផលឥណទានខ្នាតតូចមានលក្ខណៈស៊ាំញ៉ាំ នឹងមានលក្ខណៈនៃការវិនិច្ឆ័យសិទ្ធិដែលអាចទទួលបានឥណទានមានភាពតឹងរឹងពេកដាក់ស្តែងដូចជា អាជីវករទើបតែចាប់ផ្តើម អាជីវកម្មខ្នាតតូច ដូចជាអាជីវកម្មនៅក្នុងវិស័យអនឡាញដែលពួកគាត់ជាម្ចាស់អាជីវកម្មពុំមានឯកសារគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធនាគារនោះទេ ប្រសិនបើធនាគារប្រតិបត្តិតាមដូចការស្នើសុំឯកសារសម្រាប់ ឥណទានសហគ្រាសធុនតូច និងមធ្យម (SME=Small & Medium Enterprises)*1

• ក្នុងការបម្រើនូវសេវាកម្មរបស់បុគ្គលិកធនាគារមួយចំនួនតូចនៅមានការខ្វះខាត ដូចជាការយឺតយ៉ាវក្នុងការបម្រើនូវសេវាកម្មជូនដល់អតិថិជនដែលអញ្ជើញទៅប្រឹក្សាក៏ដូចជាប្រើប្រាស់សេវាកម្មឥណទានដោយផ្ទាល់ដល់ការិយាល័យធនាគារសហពាណិជ្ជ ក.អ ។

• នៅក្នុងដំណើរការនៃការផ្តល់ឥណទាន មន្ត្រីឥណទានមួយចំនួនតូចនៅមានភាពយឺតយ៉ាវ ក្នុងការចុះជួបពិភាក្សាដោយផ្ទាល់ ជាមួយអតិថិជនទៅតាមការណាត់ជួបឱ្យបានទាន់ពេលវេលា ដែលជាហេតុធ្វើឱ្យមានការយឺតយ៉ាវក្នុងដំណើរការនៃការផ្តល់ឥណទាន។ទន្ទឹមនឹងនេះធនាគារគួរតែពន្យាពេលក្នុងការផាកពិន័យ ចំពោះការបង់ប្រាក់យឺតយ៉ាវរបស់អតិថិជនតាមដែលអាចធ្វើទៅបាន ដោយអាស្រ័យទៅលើបរិបទណាមួយដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចជាតិ។

•មន្ត្រីឥណទានមានការបន្ធូរបន្ថយច្រើនចំពោះអតិថិជនចាស់ដោយមិនធ្វើការសិក្សាឡើងវិញទៅលើលទ្ធភាពសង ដែលជាហេតុបណ្តាលឱ្យកើតមានហានិភ័យឥណទាន។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីអំពី "ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារសហពាណិជ្ជ ក.អ សាខាម៉ៅសេទុង" រួចមកក្រុមយើងខ្ញុំបានសង្កេតឃើញថា ធនាគារសហពាណិជ្ជ ក.អ គឺជាធនាគារមួយដែលមាន ទស្សនវិស័យ បេសកកម្ម និងវប្បធម៌ការងារល្អក្នុងការអភិវឌ្ឍ នឹងលើកកម្ពស់នូវកំណើនសេដ្ឋកិច្ចជាតិ។ ម្យ៉ាងវិញទៀតយើងអាចសន្និដ្ឋានបានថា ធនាគារសហពាណិជ្ជ ក.អ គឺជាស្ថាប័នហិរញ្ញវត្ថុមួយដែលបម្រើនូវសេវាឥណទាន ជូនដល់អតិថិជនគ្រប់លំដាប់ថ្នាក់ ទូទាំងរាជធានីខេត្ត-ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះហើយទើបធ្វើឱ្យ ធនាគារសហពាណិជ្ជ ក.អ តែងតែបន្តក្នុងការអភិវឌ្ឍនូវសេវាឥណទានរបស់ខ្លួនឥតឈប់ឈរ តាមរយៈការដាក់ចេញនូវផលិតផលឥណទានយ៉ាងសំបូរបែប ដើម្បីបំពេញនូវតម្រូវការរបស់អតិថិជន ក៏ដូចជាសាធារណជនដែលមានបំណងក្នុងការប្រើប្រាស់នូវសេវាឥណទានរបស់ធនាគារ។ ព្រមជាមួយគ្នានេះដែរធនាគារក៏មានបុគ្គលិកប្រកបទៅដោយចំណេះជំនាញនឹងវិជ្ជាជីវៈច្បាស់លាស់ព្រមទាំងមានក្រមសីលធម៌ល្អក្នុងការបម្រើសេវាកម្មជូនដល់អតិថិជនថែមទៀតផង។

ទន្ទឹមនឹងនេះរាល់ដំណើរការនៃការផ្តល់ឥណទានរបស់ "ធនាគារសហពាណិជ្ជ ក.អ ត្រូវបានអនុវត្តទៅតាមគោលនយោបាយក្នុងការផ្តល់ឥណទាន ក៏ដូចជាដំណាក់កាលនីមួយៗដែលធនាគារបានកំណត់ឡើង ដូចជា ការដាក់ពាក្យស្នើសុំឥណទាន ការចុះពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន (5Cs 4Rs) ការផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន ការរៀបចំឯកសារឥណទាន ការអនុម័តឥណទាន ការរៀបចំកិច្ចសន្យា ការរៀបចំបញ្ចូលទិន្នន័យ និងការបញ្ចេញឥណទានទៅកាន់អតិថិជនដោយអនុវត្តស្របទៅតាមគោលនយោបាយរបស់ធនាគារដែលបានកំណត់ឡើង ដើម្បីបញ្ចៀសក៏ដូចជាកាត់បន្ថយនៃការកើនឡើងនូវហានិភ័យឥណទានដែលបណ្តាលឱ្យធនាគារមានការខាតបង់។

ជាពិសេស ធនាគារសហពាណិជ្ជ ក.អ ក៏បានចូលរួមចំណែកក្នុងការជម្រុញឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើនទៅមុខ ក៏ដូចជាចូលរួមចំណែកក្នុងការជួយលើកស្ទួយនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋព្រមជាមួយគ្នានេះដែរ ក៏បានចូលរួមក្នុងការបង្កើននូវថវិការជាតិតាមរយៈការចាក់បញ្ចូលនូវឥណទានដែលមានអត្រាការប្រាក់ទាបជាងដៃគូប្រកួតប្រជែងចូលមកក្នុងសេដ្ឋកិច្ច ដើម្បីទាក់ទាញនូវវិនិយោគិនជាតិ និងអន្តរជាតិឱ្យមកធ្វើការវិនិយោគក្នុងប្រទេសយើងឱ្យកាន់តែច្រើនឡើងថែមទៀត។

សរុបសេចក្តីមកទោះបីជាធនាគារមានការរីកចម្រើនក៏ពិតមែន ប៉ុន្តែធនាគារក៏ជួបប្រទះនូវហានិភ័យមួយចំនួនតូច ដែលបណ្តាលមកពីអតិថិជនខកខានក្នុងការសងប្រាក់ត្រឡប់មកកាន់ធនាគារវិញដែរ។ល។ ហេតុនេះហើយទើបរាល់ដំណើរការនៃការផ្តល់ឥណទានរបស់ ធនាគារសហពាណិជ្ជ ក.អ ត្រូវបានអនុវត្តឡើងទៅតាមគោលនយោបាយ ក៏ដូចជានីតិវិធីច្បាស់លាស់នៅក្នុងការផ្តល់ឥណទានដែលបានកំណត់ឡើងទៅតាមប្រភេទរបស់ផលិតផលឥណទាននីមួយៗ ទាំងនេះហើយដែលធ្វើឱ្យធនាគារសហពាណិជ្ជ ក.អ

ក្លាយខ្លួនទៅជាធនាគារពាណិជ្ជមួយដែលទទួលបាននូវកេរ្តិ៍ឈ្មោះល្អរួមទាំងទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់ សាធារណជនគ្រប់មជ្ឈដ្ឋាន។

## ៥.២ ការផ្តល់អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមកទៅលើដំណើរការនៃការផ្តល់ឥណទានរបស់ ធនាគារសហពាណិជ្ជ ក.អ សាខាម៉ៅសេទុង យើងបានសង្កេតឃើញថា សេវាឥណទានរបស់ ធនាគារសហពាណិជ្ជ ក.អ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ព្រមទាំងទទួលបាននូវការគាំទ្រពីសំណាក់អតិថិជនគ្រប់មជ្ឈដ្ឋាន។ ទន្ទឹមនឹងការចូលរួមចំណែករបស់ឥណទាន ក្នុងការជម្រុញឱ្យសេដ្ឋកិច្ចជាតិកាន់តែមានភាពរីកចម្រើនទៅមុខផងដែរ ក្រុមយើងខ្ញុំសូមការអនុញ្ញាតក្នុងការចូលរួមផ្តល់ជាមតិយោបល់ខ្លះៗ ក៏ដូចជាគំនិតដ៏ស្ចួចស្តើងដូចខាងក្រោម៖

- ធនាគារគួរតែធ្វើការសិក្សាឡើងវិញទៅលើលក្ខណៈនៃការស្នើសុំឥណទាន ក៏ដូចជាមានលក្ខណៈនៃការវិនិច្ឆ័យសិទ្ធិដែលអាចទទួលបាននូវឥណទានខ្នាតតូច កុំមានលក្ខណៈស្មុំញ៉ាំពេក ។
- ក្នុងការបម្រើនូវសេវាកម្មរបស់បុគ្គលិកធនាគារគួរតែពិចារណាឡើងវិញ ព្រោះថាបើសេវាកម្មយើងល្អក៏ជាផ្នែកមួយជួយអោយអតិថិជនមានភាពកក់ក្តៅ មានទំនុកចិត្ត ហើយក៏ជាភាពទាក់ទាញមួយទៅដល់ធនាគារផងដែរ។
- អ្នកគ្រប់គ្រងគួរតែមានការសើបអង្កេតចំពោះ មន្ត្រីឥណទានមួយចំនួនតូចដែលមានភាពយឺតយ៉ាវក្នុងការចុះជួបពិភាក្សាដោយផ្ទាល់ ជាមួយអតិថិជនទៅតាមការណាត់ជួបឱ្យបានទាន់ពេលវេលា ដែលជាមូលហេតុធ្វើឱ្យមានភាពយឺតយ៉ាវក្នុងដំណើរការនៃការផ្តល់ឥណទាន។ ទន្ទឹមនឹងនេះធនាគារគួរពន្យាពេលនៃការផាកពិន័យ ចំពោះការបង់ប្រាក់យឺតយ៉ាវរបស់អតិថិជនដោយសារបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច បញ្ហាសង្គ្រាមដែលនាំអោយពិភពលោកជួបបញ្ហាសេដ្ឋកិច្ច ហើយវាក៏ជាមូលហេតុដែលប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ចប្រទេសកម្ពុជាយើងផងដែរ។
- ធនាគារគួរតែធ្វើការត្រួតពិនិត្យបន្ថែមចំពោះមន្ត្រីឥណទានមួយចំនួនតូច ដែលមានការបន្ធូរបន្ថយច្រើនចំពោះអតិថិជនចាស់ ដោយមិនធ្វើការសិក្សាឡើងវិញទៅលើលទ្ធភាពសងរបស់អតិថិជន។

# ឯកសារយោង


1. យោងតាមសម្តីរបស់មន្ត្រីឥណទាន ឈ្មោះ ម៉ៅ ម៉េងផ័ន ថ្ងៃចុះសម្ភាសន៍ ថ្ងៃទី២៥ ខែ០១ ឆ្នាំ២០២៥
2. រៀបរៀងដោយនិស្សិត ប៉ុង ដាលីន, វុទ្ធី ស៊ីវមី, ហាវ តាក់, ឆាយ រដ្ឋា, វ៉ាន់គឹមជូ. (ឆ្នាំ២០២២). *ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០. វិទ្យាស្ថានវ៉ាន់ដា. ទំព័រទី៧. ភ្នំពេញ។
3. រៀបរៀងដោយនិស្សិត អាត គីមម៉ី, ង៉ែត សេងហួយ, សឿង ស្រីម៉ី, អ៊ឹម ដានីត, ប៉ាក ស្រីនាត. (ឆ្នាំ២០២២). *ដំណើរការនៃការផ្តល់ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុ អេ អ៊ឹម ខេ.* សារណារបញ្ចាប់ថ្នាក់បរិញ្ញាបត្រ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រ០៥-ទំព័រ០៦. ភ្នំពេញ។
4. រៀបរៀងដោយនិស្សិត. បូដាលីន និង នឹន វិបុល. (បោះពុម្ពឆ្នាំ២០១៩). *"ដំណើរការនៃការផ្តល់ឥណទានឈ្មោះអ្នកចងក្រង"* សារណាថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភិមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ទំព័រ១២. ភ្នំពេញ។
5. ងួន ហេង. (បោះពុម្ពឆ្នាំ២០២៣). *ដំណើរការនៃការផ្តល់ឥណទានខ្នាតតូច និងមធ្យមរបស់គ្រឹះស្ថានហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី.* សារណាថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភិមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ទំព័រ ៤១
6. រៀបរៀងដោយនិស្សិត ថន ស្រីពេជ្រ. (បោះពុម្ពឆ្នាំ២០២២). *ដំណើការនៃការស្វែងរកអតិថិជនក្នុងការផ្តល់ប្រាក់កម្ចី.* សារណាបញ្ចប់ថ្នាក់បរិញ្ញបត្រនៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រង. ទំព័រ១០. ភ្នំពេញ។
7. វិទ្យាស្ថាន វ៉ាន់ដា. (២០១៧). *រូបិយវត្ថុ និងធនាគារ ភាគ២.* បោះពុម្ពលើកទី៤. ទំព័រ៩. ភ្នំពេញ។
8. Process model. Scott Baird (2024). *"What is Process?"* Retrieved March, 02 2025 from https://www.processmodel.com/blog/what-is-a-process/
9. Eyelit Technologies. (2021, May 5). *What are type of Process?* Retrieved March, 02 2025 from https://www.google.com/search?q=what+are+type+of+process
10. Axel Vanhooren. (2021, June 17). *Type of Process*. Retrieved March, 02 2025 from https://www.linkedin.com/pulse/five-types-processes-axel-vanhooren
11. Amit Kothari. (2025, April 20). *What are type of Business Process Exists.* Retrieved March, 02 2025 from https://tallyfy.com/types-of-business-processes/
12. CT.gov. (2020, June 5). *Bank*. Retrieved March, 02 2025 from https://portal.ct.gov/dob/consumer-education/abcs-of-banking---banks-and-our-economy
13. WIKIPEDIA. Last Edit. (2025, April 21). *History of Banking* Retrieved March, 05 2025 from https://en.wikipedia.org/wiki/History_of_banking#References
14. Facebook Page. TOLA Banking. (2020, July 05). *តើឥណទានជាអ្វី?*. Retrieved June, 04 2025 from https://www.facebook.com/share/p/1DkDcay5MB/
15. Pipefy. (2021, June 7). *What is a Procedure*. Retrieved June, 06 2025 from https://www.pipefy.com/blog/process-vs-procedure/
16. Gluu. (2018, April 19). *What is Procedure.* Retrieved June, 06 2025 from https://gluu.biz/process-management-glossary/procedure/
17. Linknedin. (Jan 24, 2016). *A Brief History of Procedure.* Retrieved June, 06 2025 from https://www.linkedin.com/pulse/brief-history-procedures-kevin-mcmanus
18. KHsearch. ការគ្រប់គ្រង់. (2020, May 29). *តើការគ្រប់គ្រងយុទ្ធសាស្ត្រគឺជាអ្វី?*. Retrieved June, 06 2025 from https://www.khsearch.com/qna/31420
19. របាយការណ៍ប្រចាំឆ្នាំ២០២៣ (Annual Report) របស់ធនាគារ CUB. https://www.esunbank.com/en/-/media/New-ESUNBANK/business/corporate/overseas-branch/UCB/Annual_Report/2023_Annual_KH

# 20. ឧបសម្ព័ន្ធទី១

## ទីតាំងផ្ទាល់របស់ធនាគារសហពាណិជ្ជ ក.អ សាខាអាំងទែកុងទីណង់តាល់




## ការចុះសម្ភាសន៍ដោយផ្ទាល់ជាមួយមន្ត្រីឥណទានរបស់ធនាគារ សហពាណិជ្ជ ក.អ



**ដំណាក់កាលទី៣៖** ការចុះអង្កេតនិងវាយតម្លៃអតិថិជន។ ភ្នាក់ងារឥណទានចុះសាកសួរអ្នករស់នៅជិតអតិថិជនដោយមិនបង្ហាញពីគោលបំណងឬ សមាសភាពពិតប្រាកដក្នុងគោលបំណងទទួលបានព័ត៌មានពិតពីអតិថិជន។ បន្ទាប់មកភ្នាក់ងារឥណទានត្រូវ៖

- ជួបអតិថិជនតាមការណាត់
- ពិនិត្យសកម្មភាពមុខរបរ និងទ្រព្យសម្បត្តិដាក់បញ្ចាំរបស់អតិថិជន
- ធ្វើគំរោងជំនួញតាមសភាពជាក់ស្តែងនៃមុខរបរអតិថិជន
- ស្នើសុំអតិថិជនដាក់លិខិតសម្គាល់ម្ចាស់កម្មសិទ្ធិច្បាប់ដើមដំកល់ទុក និងចេញបង្កាន់ដៃដាក់ដំកល់ប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិជូនអតិថិជន
- ចុះជួបអ្នកធានា ដើម្បីពិនិត្យស្ថានភាពដែលអាចធានាបាន
- ពន្យល់អ្នកធានាពីការទទួលខុសត្រូវរបស់គាត់
- សាកសួរអ្នកធានាបន្ថែមពីទំនាក់ទំនងជាមួយអតិថិជន
- សាកសួរព័ត៌មានបន្ថែមពីសាច់ញាតិ អ្នកផ្គត់ផ្គង់ និងអតិថិជនរបស់គាត់
- បញ្ចប់ការបំពេញពាសន្លឹកចុងក្រោយនៃពាក្យស្នើសុំឥណទាន
- វិភាគនិងផ្ទៀងផ្ទាត់ព័ត៌មានទទួលបានតាមប្រភពផ្សេងៗ
- វាយតម្លៃពាក្យស្នើសុំឥណទាននូវចំណុចមួយចំនួនដូចជា ប្រវត្តិអតិថិជនប្រវត្តិនៃការសងត្រឡប់វគ្គមុន (អតិថិជនចាស់ ) លក្ខណៈអត្តចរិតរបស់អតិថិជន និង គោលបំណងនៃការប្រើប្រាស់
- វាយតម្លៃលទ្ធភាពសងពីផលចំណេញលើមុខរបររបស់អតិថិជនពិនិត្យកម្រិតជីវភាពរស់នៅ និងទំហំ ទ្រព្យសម្បត្តិទាំងអស់របស់អតិថិជន
- ពិនិត្យលើទ្រព្យធានាបំណុល និងអ្នកធានាបំណុល
- វាយតម្លៃលើស្ថានភាពទីផ្សារលើមុខរបររបស់អតិថិជន និងការប្រែប្រួលសេដ្ឋកិច្ចនិងនយោបាយ។

**ដំណាក់កាលទី៤៖** ការអនុម័តឥណទាន។ ប្រធានផ្នែកឥណទានត្រូវសង្ខេបព័ត៌មានពីអតិថិជនជូន សមាជិកគណកម្មាធិការឥណទាននិងស្នើសុំយោបល់ពីសមាជិកគណកម្មាធិការឥណទាន។ បន្ទាប់មកគណកម្មាធិការឥណទានប្រចាំសាខាបានផ្តល់យោបល់លើសំណើរសុំអនុម័តឥណទាន ដែលអាចមាន២ករណីគឺ ៖

- ករណីទី១ គឺបដិសេធការស្នើសុំឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា រក្សាទុកឯកសារមិន បានអនុម័តរួចផ្តល់ចម្លើយទៅភ្នាក់ងារ។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយដោយបដិសេធ សំណើរសុំឥណទានទៅកាន់អតិថិជន និងរៀបចំដកប័ណ្ណកម្មសិទ្ធិជូនអតិថិជនវិញ។
- ករណីទី២ គឺយល់ព្រមអនុម័តឥណទាន។ ប្រធានផ្នែកឥណទានប្រចាំសាខា ត្រូវផ្តល់ចម្លើយទៅអោយ ភ្នាក់ងារឥណទាន។ បន្ទាប់មកភ្នាក់ងារឥណទានបានផ្តល់ចម្លើយយល់ព្រមអនុម័តឥណទាន ជូនអតិថិជន។

**ដំណាក់កាលទី៥៖** ការរៀបចំឯកសារឥណទាន ។ ភ្នាក់ងារឥណទានត្រូវ៖

- រៀបចំកិច្ចសន្យាខ្ចីប្រាក់ និងកិច្ចសន្យាដាក់បញ្ចាំ ផ្ទេរសិទ្ធិគ្រប់គ្រងនិងយល់ព្រមលក់ទ្រព្យបញ្ចាំនិងអានពន្យល់ឲ្យមានច្បាស់លាស់ជូនអតិថិជន និងអ្នកធានា ស្តាប់មុននឹងផ្តិតមេដៃ
- ឲ្យអតិថិជន និងអ្នកធានាផ្តិតមេដៃនៅចំពោះមុខលើកិច្ចសន្យាទាំងអស់ និងអត្តសញ្ញាណប័ណ្ណថត ចម្លងរួមទាំងចុះកាលបរិច្ឆេទផងដែរ
- ស្នើឲ្យអតិថិជន យកឯកសារទៅបញ្ជាក់អជ្ញាធរមូលដ្ឋាន